# ការសម្ភាសន៍របស់អ្នកមីងទៀង  គឹមអ៊ីន

កៈ  អ្នកសម្ភាសន៍ឈ្មោះ  គួច  សុម៉ាលី          ខៈ  អ្នកត្រូវបានគេសម្ភាសន៍ឈ្មោះ ទៀង  គឹមអ៊ីន

កៈ  ឥឡូវជាដំបូងខ្ញុំសូមជំរាបសួរអ្នកមីង  ហើយខ្ញុំមកពីខាងសាលាសកលវិទ្យាល័យ BYU មកធ្វើបទសំភាសន៍មីងពីប្រវត្តិផ្ទាល់ខ្លួន។  ហើយអញ្ចឹងសុំអ្នកមីងចូលរួមឆ្លើយនឹងសំនួរបាន ទេអ្នកមីង?

ខៈ  បាន។

កៈ  ចាំ  !  អញ្ចឹងអើ..  អើ..  ជាដំបូងខ្ញុំសូមប្រាប់ថាអើ..ខ្ញុំសូមប្រាប់ឈ្មោះរបស់ថាខ្ញុំ ឈ្មោះគួច  សុម៉ាលី  ។  ហើយចង់សួរអ្នកមីងថាអ្នកមីងឈ្មោះអ្វីដែរ?

ខៈ  ទៀង  គឹមអ៊ីន។

កៈ  ទៀង  គឹមអ៊ីន?

ខៈ  គឹមអ៊ីន។

កៈ  គឹមអ៊ីន?

ខៈ  គឹមអ៊ីន។

កៈ  ទៀងគឹមអ៊ីន  អើ..  អ៊ឹមឈ្មោះនៅក្នុងបញ្ជីជាតិទេអ្នកមីង?

ខៈ  ក្នុងបញ្ជីជាតិ។

កៈ  អញ្ចឹងអើ..  អ្នកមីងមានឈ្មោះហៅខាងក្រៅទៀតទេ?

ខៈ  ឈ្មោះងាំ។

កៈ  ឈ្មោះ?

ខៈ  ឈ្មោះមីងងាំ។

កៈ ឈ្មោះមីងងាំ?

ខៈ ហ្នឹងហើយ។

កៈ ឈ្មោះមីងងាំ។

ខៈ អែម........... (ក្រហែម)។

កៈ អញ្ចឹងអ្នកមីងមានរហ័សនាមអ្វីហៅក្រៅទៀតទេ?

ខៈ អត់មានទេមានតែប៉ុណ្ណឹង។

កៈ ចា៎ អញ្ចឹងកាលពីក្មេងមកអ្នកមីងមានគេ មានឈ្មោះដែលគេដាក់ហៅក្មេងៗដូចគ្នាហៅអីអត់មានទេអ្នកមីង?

ខៈ អត់មានឈ្មោះ ឈ្មោះមានតែពីរហៅសព្វថ្ងៃឈ្មោះងាំនឹងមួយហើយនឹងនៅក្នុងបញ្ជីជាតិនឹងមួយ។

កៈ ចា៎។

ខៈ ហ្នឹងហើយ។

កៈ ចា៎ អញ្ចឹងអើ.. ឥឡូវអ្នកមីងអាយុប៉ុន្មានហើយឆ្នាំនឹង?

ខៈ អាយុហាប្រាំពិល(៥៧)។

កៈ ហាប្រាំពិល(៥៧) ! អ្នកមីងកើតនៅក្នុងថ្ងៃខែឆ្នាំណាដែរ?

ខៈ ហ៊ឺម...!សួរមីងរឿងកើតមីងចប់ហើយ គ្រាន់តែដឹងតែអាយុហើយនឹងឆ្នាំ។

កៈ អញ្ចឹងមីងអត់ចាំឆ្នាំកំណើតទេនែស។

ខៈ អត់! ត្រូវអាបញ្ជីជាតិកំណើតនឹងកាលរើផ្ទះនឹងទៅ គិតផ្ទះទឹកលិចទៅនៅជាមួយកូនធ្វើការនៅអីភ្នំពេញនឹងវាកណ្ដុរវាស៊ីអស់អាលីងទៅ រកតែបញ្ជីកំណើតកូនបញ្ជីកំណើតអីគ្មាន ទើបអ៊ុំនឹងធ្វើអោយទៅបាត់អារបស់ឯងទើបរើផ្ទះរើអីនឹងផ្ទះទឹកលិចអស់នឹងទៅ បីបួនកាំជណ្ដើរនឹងទៅបិទតែទ្វារចោល ទៅនៅដាំបាយអោយកូននៅភ្នំពេញនឹងទៅ ក៏វាកណ្ដុរវាស៊ីតាំងមិនត្រឹមតែនេះទេ ខោអាវអីមុងអីអស់អាលីង បានជាវាលិចទឹកឡើងបួនកាំជណ្ដើរ

ទៅហើយ គេជិតខាង គេចាក់មួយឆ្នាំៗឯងរកតែលុយចាក់គ្មានរវល់តែឈឺរួចកូនទើបធ្វើការរោងចក្រឈប់រៀនបានតែថ្នាក់ត្រឹមទីបួន កូនទៅស៊ីឈ្នួលគេទាំងពីទាំងបី មានស្អីទៀត។

កះ ចាំ អញ្ចឹងអ្នកមីងអត់ចាំឆ្នាំកំណើត?

ខះ អត់មានចាំទេក្មួយ។

កះ ចាំ។

ខះ នឹងកើត អាយុកើតទេ អាយុកើតឆ្នាំជូតដឹងតែប៉ុណ្ណឹងទេ ហើយដឹងតែអាយុហាជាង។

កះ ចាំ។

ខះ ជូតជាងហានឹងណាស់បែបជាចូលហាប្រាំបី(៥៨)ហើយឆ្នាំថ្មីនឹងហាស។

កះ ហាប្រាំបី?

ខះ ហាប្រាំបីឆ្នាំថ្មីនឹងហើយ។

កះ អញ្ចឹងឆ្នាំជូតនឹងអើ.. តំណាងអោយសត្វ សត្វកណ្ដុរ?

ខះ កណ្ដុរ។

កះ មីងឆ្នាំកណ្ដុរ?

កះ ចាំ។

ខះ កណ្ដុរដើមឆ្នាំគេលេខមួយ កណ្ដុរលេខមួយណា។

កះ ចាំ។

ខះ ហ្នឹងហើយ។

កះ អញ្ចឹងអ្នកមីងអើ.. តើទីកន្លែងកំណើតកើតនៅឯណាដែរ?

ខះ ហ៊ឹម... មីងស្រុកកំណើតកើតមកពីម៉ែពីឪមកឬសកែវនៅនឹងម៉ង។

កះ នៅឯណា?

ខ៖ នៅនឹងម៉ង។

ក៖ នៅខេត្តណាដែរ?

ខ៖ នៅចំការលើស្វាយទាបនឹងតាម៉ង។

ក៖ អរ... ខេត្តកំពង់ចាម?

ខ៖ ខេត្តកំពង់ចាម។

ក៖ ស្រុក?

ខ៖ ស្រុកចំការលើ ឃុំស្វាយទាប ភូមិវារីកើត។

ក.អ... ចាំ។

ខ៖ ហ្នឹងហើយ។

ក៖ ហើយអ្នកមីងនៅក្នុងក្រុមគ្រួសារមានសមាជិកក្រុមគ្រួសារប៉ុន្មាននាក់?

ខ៖ មីងកូនបួននាក់ប្រាំនាក់ទាំងម្ដាយឪពុកអត់មានទេបែកតាំងពីប៉ែតប្រាំមួយ៕

ក៖ មីងអើ....ចំពោះអ្នកមីងផ្ទាល់បងប្អូនមីងមានប៉ុន្មាននាក់ដែរ?

ខ៖ ឥឡូវយើងនិយាយតែនៅរស់ៗទៅណ៎? មើលឈប់សិនរាប់សិន អ៊ុំហ៊ាន អ៊ុំហួននៅតែបួននាក់។

ក៖ អ្នករស់នៅបួននាក់?

ខ៖ នៅបួននាក់។

ក៖ គាត់ឈ្មោះអ្វីខ្លះ?

ខ៖ ឈ្មោះទៀងហ៊ាន ទៀងហួន ទៀងហុង ទៀងគឹមអ៊ីននឹង។

ក៖ ចាំ។

ខ៖ ហ្នឹងហើយ។

ក៖ ចុះអ្នកដែលស្លាប់នឹងគាត់ប៉ុន្មាននាក់ដែរមីង?

ខ៖ ស្លាប់ជំនាន់ប៉ុលពតនឹងអ្នកចិតប្រាំនឹងតែមួយទេ ហើយក្រៅពីនឹងស្លាប់នឹងជំងឺ មើល ប៉ែត ប៉ែតគត់ចុងប៉ែតគត់នឹង ស្លាប់មួយ ដល់មកម៉ែតុលានឹងទីប្រាំទីប្រាំមួយនឹងស្លាប់នឹងខ្សែរភ្លើងឆក់។

ក៖ ចាំ។

ខ៖ នឹងអញ្ចឹងទាំងអស់មានបងប្អូនទាំងស្លាប់ទាំងរស់បួននាក់ប្រាំមួយនាក់។ប្រាំពិល(៧)នាក់ទាំងអស់។

ក៖ ប្រាំពិល(៧)នាក់។

ខ៖ ប្រាំពិល(៧) មួយឆ្កែឆ្កួតខាំ។

ក៖ មួយទៀតឆ្កែខាំ?

ខ៖ ឆ្កែខាំ។

ក៖ អញ្ចឹងអើ.... បងបង្អស់គាត់ឈ្មោះអ្វីដែរ?

ខ៖ ឈ្មោះទៀងហ៊ន។

ក៖ ទៀងហ៊ន?

ខ៖ ទៀងហ៊ន។

ក៖ ចុះទីពីរ?

ខ៖ ទីពីរឈ្មោះទៀងហួន។

ក៖ ទៀងហួន?

ខ៖ ទីពីរអានឹងយើងនិយាយតែនៅរស់ទេណា។

ក៖ ចាំ។

ខ៖ ទីពីរនែក...ប្រុស វាយចិតប្រាំ(ឆ្នាំ១៩៧៥)ចោល។

កៈ  មីង  មីងជួយរៀបរាប់អើ...  តាមលំដាប់បានទេទាំងអ្នកស្លាប់ទាំងអ្នករស់។

ខៈ  អញ្ចឹងហ៎.....?

កៈ  ចា៎។

ខៈ  អើទាំងស្លាប់ហ៎!  អើ..  ទីមួយទៀងហ៊ន  ទីពីរនែក..  ឈុនឈាង។

កៈ  ឈុនឈាង?

ខៈ  ទៀងឈុនឈាង។

កៈ  ទៀងឈុនឈាង?

ខៈ  ហ្នឹងហើយ  ទៀងឈុនឈាង  ហើយមក  ទៀងហ៊ុន  ទៀងហៀង  ទៀងហុង  ទៀង  ហាន  ទៀងគឹមអ៊ីន  ទៀងសម្បត្តិ  ប្រាំបី។

កៈ  អញ្ចឹងមីងបន្ទាប់ពៅ?

ខៈ  ប្រាំបួន  ប្រាំបួននែក...ឈ្មោះបងហ៊ឹបមួយទៀតនឹងមីងកើតអត់ទាន់ទេនែកមីងលឺតែឈ្មោះទេនឹងឆ្កែឆ្កួតខាំប្រាំបួន។

កៈ  អរ....  ចា៎។

ខៈ  ហ្នឹងហើយប្រាំបួននាក់។

កៈ  អញ្ចឹងមីងកូនទីប្រាំបី?

ខៈ  មីងទីប្រាបី។

កៈ  កូនទីប្រាំបី។

ខៈ  ប្អូនពៅប្រុសស្លាប់នឹង  ទៀងសម្បត្តិនឹង។

កៈ  ទៀង  សម្បត្តិស្លាប់  អញ្ចឹងអ្នកមីងមានចាំសាច់រឿងពីពួកគាត់ខ្លះទេ?  អ្នកមីងអាចរៀបរាប់បានទេ?

ខ៖ អរ.. ឥឡូវគាត់ពិបាកណាស់ក្មួយអើយសុទ្ធតែលំបាក បងទីមួយនឹងឥឡូវអាយុ មើលកាលប៉ែតប្រាំមួយនឹងណាស់។

ក៖ ចាំ។

ខ៖ ប៉ែតប្រាំមួយនឹងផ្ទះគាត់នឹងគេសុំធ្វើទីស្នាក់ការ ពួកខេត្តគេចុះមកអញ្ចឹងទៅនៅកន្លែងមន្ទីស្រុក នឹងគេសុំកន្លែងគាត់និងមកធ្វើការ ថ្ងៃឡើងគេមកធ្វើការនៅនឹងយប់គេទៅដេកនៅកន្លែងមន្ទីស្រុក រួចទៅអាពតណាស់វាដឹងថាផ្ទះយើងបម្រើពួកនឹងណាស់អោយពួកនឹងនៅស្នាក់ គប់គ្រាប់បុកអាបេ បុកអាបេណាស់ពីក្រោយផ្ទះមកគ្រោះថ្នាក់កូនពៅមួយ ពីរនាក់ទៀតជរាពិការត្រូវរបួស។

ក៖ កាលនឹងឆ្នាំណាដែរមីង?

ខ៖ ឆ្នាំប៉ែតប្រាំមួយ (១៩៨៦)។

ក៖ អរ...មួយពាន់ប្រាំបួនរយប៉ែតប្រាំមួយ(១៩៨៦)។

ខ៖ ដឹងមួយពាន់ប្រាំបួនរយប៉ុន្មាន មីងដឹងតែប៉ែតប្រាំមួយទេ។

ក៖ ចាំ។

ខ៖ ប៉ែតប្រាំមួយ ប៉ែតប្រាំមួយនឹង
ពេញហើយគាត់ គាត់លំបាកតាំងពីនឹង លក់ផ្ទះលក់អីមើលកូន លក់ដីចម្ការដីធ្លីអស់ផ្ទះលក់អោយគេមួយជំនាន់នឹងហើយណាស់។

ក៖ ចាំ...មីង។

ខ៖ បានបីតម្លឹង បីតម្លឹងមើលផ្ទះដីឥឡូវលក់បានបួនដប់ម៉ឺនអត់ខ្វះទេក្មួយអើយ គាត់វេទនាណាស់សព្វថ្ងៃនឹងនោះពឹងកូនឯណា កូនសុទ្ធតែជរាពិការ លក់ឈាមមាន់ឈាមជ្រូកជៀនតិចតួច ជិះកង់ទៅវិលដួលទៅរហូតតាប៉ុម អញ្ចឹងទៅទូលទៅដើរទៅរាប់គីឡូដីបួនប្រាំគីឡូដីអាណិតបងខ្លោចចិត្ត ប៉ុន្តែមិនដឹងមានអីជួយគាត់បើខ្លួនឯងជរាឈឺ ក្មួយឯងគិតមើលមួយខែៗចិញ្ចឹមតែថ្នាំកូនមិនដែលបានអីទេ យកមកគំនិតបម្រុងអោយតែម៉ែថ្នាំផងចិញ្ចឹមស៊ីផង អីផងនឹងគ្មានអីទេ រួចបងទីបីនឹង យើងថាទីបីចុះ អ្នកនៅរស់ណាស់។

ក៖ ចាំ។

ខ៖ អើ... ដែលអាអ្នកងាប់នឹងវាទីពីរ ទីបីគាត់នឹង វាគាត់គួរសម គេកូនគេវាមានការងារអីធ្វើអញ្ចឹងទៅគេផ្ទុងផ្ដើមគំនិតបម្រុងទៅ គាត់ធ្វើស្អីៗកំប៉ិកកំប៉ុកលក់អញ្ចឹងទៅអ៊ុំហ៊ុនហ៎ណាស់។

ក៖ ចា៎។

ខ៖ ទៀង ហ៊ុន នោះហើយមកបន្ទាប់មកទៀងហុងនឹង គាត់ក៏គ្មានរកអីធ្វើអីជំងឺជរាដូចតែមីងអញ្ចឹងមានអី បានកូនចិញ្ចឹមទេគ្មានអីទេទៅរកស៊ីឯណា នៅតែម៉ាដាំបាយមើលចៅមើលអីនឹងគ្មានបានធ្វើអីទេវ៉ាប់រងចៅរៀនមើលដាំបាយដាំអីនឹងកូនទៅធ្វើការមើលចៅមើលអីនឹងបន្ទាប់មក មកក៏មីងនឹង មើលទៅឃើញហើយសព្វថ្ងៃមានតែផ្ទះមួយជំរកប៉ប៉ុននឹង(តែប៉ុន្នឹង) រកតែផ្លូវដើរគ្មានធ្វើផ្ទះនឹងថាអាងតែផ្លូវសាធារណៈបានជាធ្វើផ្ទះនៅប៉ប៉ុនមួយប្រលោះខ្លួននឹងផ្ទះប្រាំមួយម៉ែត្រនឹងទទឹងនឹង ដល់ឥឡូវគេលោភលន់ជិតខាងនឹងវាលោភលន់យកដី កម្មមិនមែនកម្មសិទ្ធិខ្លួនឯងយកទៅធ្វើជាកម្មសិទ្ធិនឹងទៅ គេគ្មានអាណិតអាសូរយើងគេធ្វើដោយបំពាន បើអ្នកគិតឃើញគេមិនយកទេក្មួយអើយ ក្មួយឯងមើលផ្លូវមានឯណាផ្លូវចេញចូល យប់គេបិទថ្ងៃគេបើកអោយដើរទៅដូចអ្នកទោសអញ្ចឹង
រួចដីមិនមែនកម្មសិទ្ធិរបស់វាទេដីនេះ ដីផ្លូវកើតតាំងពីមុនម៉ែឪវាកើតទៅទៀត។អញ្ចឹងគ្មានអីទេសព្វថ្ងៃទីពឹងបានតែកូនមួយនឹង ក្រៅពីនឹងគ្នាក៏នៅពិបាកមិនទាន់មានផ្ទះមានសំបែងបានកូនពៅមួយនឹងជួយមើលជួយថៃរាល់ថ្ងៃនឹង ឈឺបានបងប្អូនជិតខាងនឹងទៅជួយមើលទៅបងនឹងទៅ។ សម្រាប់តែកូនបង្កើតអាល័យតែមកមើលយើងមានអីចិញ្ចឹម។

ក៖ ចា៎។

ខ៖ បើដល់ខែលុយថ្នាំណាស៊ី ណាថ្នាំមើលខ្លួនប្រចាំកាយ ថ្នាំប្រចាំនឹងទូរទឹកកកមួយខែៗអស់ប្រាក់ខែគ្នាបានប៉ុន្មានបានតិចតួចលៃយកមកអោយម្ដាយ ចិញ្ចឹម ម្ដាយជីវភាពរាល់ថ្ងៃផង ថ្នាំរាល់ខែក្មួយឯងគិតមើលឃើញហើយថ្នាំចាក់ថ្នាំពេទ្យនឹង គ្រាន់តែមួយចូលឆ្នាំនឹងក្បែៗនឹងទៅហើយនឹងវាអស់ជាតិថ្នាំ..។

ក៖ ចា៎។

ខ៖ ទាល់តែទៅពេទ្យវិញបានរស់ទៀតទៅ។

ក៖ អ្នកមីងឈឺអីដែរ?

ខ៖ មីងទឹកនោមផ្អែមប៉ុន្តែទឹកនោមផ្អែមមីងខ្លាំងដល់កំណត់ពីដំបូងមកមីងអត់ដឹងថាមីងទឹកនោមផ្អែម ទាល់តែចម្រុះមួយយប់ៗទល់ៗភ្លឺចឹងទៅអស់រាងកាយនៅតែស្បែកនឹងឆ្អឹង បានទៅដល់ពេទ្យ ពេទ្យភ្នំពេញមើលមីងអត់ជល់សោះទៅដល់នឹងពេទ្យកំពង់ធំនឹង ថាអស់លំពែងអីខ្សោយអស់អាលីង ត្រង់នឹងហើយគេទឹកនោមផ្អែមដូចមីងដែរ គេដំបៅពេទ្យថាស្រួលមើលជាងមីងទៅពេទ្យ ពេទ្យទាញចេះទៅអត់មានសាច់កំភួនអីចាក់ទៅទាញអញ្ចឹងណាស់ទាញដូចអាវយឺតអញ្ចឹងមានតែស្បែកនឹងឆ្អឹងទេ។

ក៖ ចាំ៎។

ខ៖ អង្គុយ អង្គុយមិនកើតបានតែដេកវាដល់ដំណាក់កាលទៅវាទន់ហ៎ណាស់ វាទន់ ទៅក៏បានកាក់កបមួយខែឡើងទៅថ្នាំមួយខែដឹងតែវាយថ្នាំមកលេប ម៉ាខែអស់ៗ ទៅទិញហើយទិញថ្នាំចាក់ទិញថ្នាំលេបនឹង នឹងអញ្ចឹង។

ក៖ ចាំ៎។

ខ៖ រស់នឹងថ្នាំទេ រួចពេលឈឺម្តងៗមានអីមានតែជិតខាងនឹងហើយគេដល់ម្តងៗទៅងើបមិនរួចទន់គេដាំបាយយកមកអោយស៊ីទៅ។

ក៖ ចាំ៎។

ខ៖ អានឹងអញ្ចឹងជំងឺមីងប្រចាំកាយមើលឈឺនឹងទន់នៅឡើយទេជិះកង់អត់រួចទេ។

ក៖ ចាំ៎។

ខ៖ អត់រួចទេដូចវាបាក់អស់ហើយ..។

ក៖ ចុះអ្នកមីងអើ..ពេលអើ....បងប្អូនអ្នកមីងដែលគាត់ស្លាប់នឹងគាត់ស្លាប់ដោយសារអ្វីទៅមីង?

ខ៖ ស្លាប់មើលកាលនឹង ម៉ាយើងមួយជំនាន់ប៉ៃត(១៩៨០)ចុងប៉ៃតគត់ហ៎ណាស់។

ក៖ ចាំ៎។

ខ៖ ចុងប៉ៃតគត់(១៩៨០)នឹងគាត់ចុក ចុកនឹងកាលមួយជំនាន់នឹងមានគ្មានថ្នាំណាដូចយើងអីណា។

ក៖ គាត់ គាត់បងទីពីរហ៎?

ខ៖ ហ៊ើសគាត់ គាត់បង បងទីបួនបងទីបួន។

ក៖ ចា៎។

ខ៖ ទីបួនប្រវត្តិហា៎។

ក៖ ហើយគាត់ឈឺ?

ខ៖ រួចកូន កូនទីបីហា៎គាត់ហា៎ស្លាប់ទៅកូននៅតូចៗទេ។

ក៖ ចា៎។

ខ៖ តូចៗទេរួចទៅប្តីនឹងក៏យកប្រពន្ធទៀតអញ្ចឹងទៅគេក៏មានកូនយើងក៏មានកូនទៅ កូននឹងក៏មិនបាននៅអោបក្រសោបនឹងខ្លួនទីណាត់ទីណែងទៅស៊ីឈ្នួលគេអញ្ចឹងទៅឥឡូវអាកូនគាត់ទី បងទីបួននឹងទីកូនបងគេនឹងងាប់ទៅទៀត។

ក៖ អ៎....?

ខ៖ នៅតែពីរទេពីរនឹងមួយនឹងណា៎ក៏នៅស៊ីឈ្នួលគេនៅតែក្នុងព្រៃទេក្មួយអើយ មានតែមួយជម្រក មួយខ្លួនទេកូនក៏ឧស្សាហ៍ឈឺប្តីក៏ឧស្សាហ៍ឈឺ កាប់ព្រៃទៅរានព្រៃបានអញ្ចឹងទៅបានមកកូនឈឺកូនអីអញ្ចឹងទៅប្តីឈឺទៅខ្ចីគេលិចកើតចងការគេខ្លះទៅខ្ចីគេខ្លះទៅយូរៗអត់បានរកអីសងគេអស់ដីទៀតទៅគ្មានលេងល្បែងស៊ីផឹកអីទេនៅក្នុងព្រៃវាចាញ់ណាស់។

ក៖ ចា៎។

ខ៖ វាចាញ់ ហើយដូចយើងស៊ីដូចវាមិនជិតដល់អញ្ចឹងវាខ្វះខាតអញ្ចឹងទៅយ៉ាប់ណាស់សព្វថ្ងៃនឹងនៅមួយចូលឆ្នាំជូនមកជូនអត់ម្តាយនៅងាប់នៅនែសជូនកាលអត់មានបានមកទេ។

ក៖ គាត់ស្លាប់ដោយសារអីអ្នកមីងគាត់ចុកម៉េចគាត់ឈឺហ៎?

ខ៖ ចុកឈឺ។

ក៖ គាត់មានជំងឺអីទៅ?

ខ៖ អត់មានជំងឺអីទេចាប់ចុកឈឺងាប់ឈឺចុកម៉ោងប្រាំមួយល្ងាចទល់ភ្លឺអត់មានពេទ្យអីណាក្នុយ។

ក៖ ចា៎។

ខ៖ មិនទាន់មានពេទ្យត្រឹមត្រូវទេកាលនឹងហា៎។

ក៖ ចុះបងទីពីរគាត់ស្លាប់ដោយសារអីដែរ?

ខ៖ បងទីពីរ បងទីពីរគាត់អ្នកចិតប្រាំ(១៩៧៥) គាត់អ្នកចិតប្រាំណាស់ ប្រុសតែពីរទេកូនបងប្អូននឹងប្រុសតែពីរទេ។

ក៖ អញ្ចឹងគាត់ស្លាប់កាលជំនាន់ប៉ុលពត?

ខ៖ ជំនាន់ប៉ុលពតគាត់អ្នកចិតប្រាំ(១៩៧៥)មកដល់ផ្ទះនឹងហើយដូចថាពីដើមមកយើងអ្នកធូរធារណាស់ពួកវានិងស៊ីឈ្នួលយើងកម្មករតាអី ទៅដេកកាប់ព្រៃកាប់អីអោយគាត់ធ្វើចំការអីមើលខុសត្រូវអីអញ្ចឹងហា៎ស ដល់មកជំនាន់អាពតនឹងគេឡើងយកអ្នកល្ងង់ឡើង ឡើងធំទៅ អ្នកចេះចុះរណ្តៅអ្នកខ្លៅឡើងឋានសួគ៌ណាស់ គេនិយាយអញ្ចឹងហ៎ណាស់។

ក៖ ចា៎។

ខ៖ វាសំលាប់អត់រើសមុខទេ ដើម្បីយកបុណ្យស័ក្តក្នុយជំនាន់អាពត។

ក៖ អ៎រ...។

ខ៖ គ្មានយល់បងប្អូនទេងាប់នេះងាប់ដោយសារដូចថាសាច់ឈាមដែរប៉ុន្តែវារៀងឆ្ងាយ ដូចទៅវាក្រជាងយើងណាស់ ដែលគេបោសសំអាតលីតែកូនយើងនៅមើលគាត់រៀននៅភ្នំពេញនឹងគាត់ទើបបានចេញធ្វើការស៊ីប្រាក់ខែ គាត់ធ្វើកាន់ខាងព្រលានយន្តហោះហ៎កាន់ខាងTOនៅប៉ូជិនតុងយើងនឹងហ៎៕

ក៖ ចា៎។

ខ៖ កន្លែងគាត់ទើបស៊ីប្រាក់ខែបានបីឆ្នាំ ទេគាត់អាយុស្លាប់នឹងអាយុសាមសិប ម៉ា(មក)ៗដាច់អាពត(ប៉ុលពត)នឹងមកផ្ទះនឹងអាយុសាមសិបហ៎គាត់អាយុសាមសិប៕

ក៖ គាត់នៅព្រលានយន្តហោះធ្វើ......?

ខ៖   កាន់ខាងTO។

ក៖   កាន់ខាងTO?

ខ៖   ហ្នឹងហើយ។

ក៖   TOនឹងគេធ្វើអីខ្លះមីង?

ខ៖   មីងលីតែពុកយើងកាលនឹងយើងនៅតូចមិនសូវដឹងគាត់ថាទើបស៊ីប្រាក់ខែបានបីឆ្នាំកាន់ខាងTOគ្រាន់តែប៉ុណ្ណឹងទេTOនឹងលឺតែនិយាយជំនាន់នឹងមីង   មិនទាន់ទាំងស្គាល់ផង៕

ក៖   ចាំ។

ខ៖   មួយជំនាន់នឹងហាំនៅតូចៗនឹង។

ក៖   ចុះបងប្អូនម្នាក់ទៀតដែលថាគាត់ស្លាប់?

ខ៖   អានឹងឆ្កែឆ្កួតខាំរួចមួយទៀតពៅគេនឹងទើបស្លាប់បានពីរឆ្នាំនឹងហ៉ែសពៅប្រុសហ្នឹងហាំ។

ក៖   ចាំ។

ខ៖   ពៅគេនឹងបន្ទាប់នឹងមីងរួចបានពៅប្រុសនឹងស្លាប់នឹងជំងឺធំពោះទៅងាប់នៅខាងប្រពន្ធន់   នៅខាងកំពង់ទ្រាសន់   រួចទៅបងប្អូនសុទ្ធតែដៃទាល់ជើងទាល់មានពីណាជួយពីណាទេក្មួយអើយ.....សក់ពីណាក្បាលពីនឹងគ្រាន់តែបានជួយអាណិតអាសូរប៉ុណ្ណឹងមានស្អីទៅងាប់នឹងកំសត់កំរណាស់ក្មួយអើយ៕

ក៖   ចុះបងប្អូនអ្នកមីងឥឡូវគាត់រស់នៅកន្លែងណាខ្លះ?អ្នកដែលនៅរស់ណាស់?

ខ៖   នៅ..និយាយដូចថានៅក្នុងសង្កាត់វិញហាំនៅក្នុងសង្កាត់ស្វាយទាបនឹងតាម៉ង(តែម្តង) គ្រាន់តែភូមិខុសគ្នាទេនៅថ្នល់បែកមួយ   ឃុំ   ឃុំថ្នល់បែក   សង្កាត់ស្វាយទាបដែរណាស់៕

ក៖   ចាំ។

ខ៖   នឹងពីរគ្រួសារ។

ក៖   ចាំ។

ខ៖   ហើយនៅភូមិវារីកើតនេះ   សង្កាត់ស្វាយទាបដែរភូមិវារីកើតពីរនាក់។

ក៖ ចាំ។

ខ៖ ទៀង ហុង ហើយនឹងទៀងគឹមអ៊ីននឹង។

ក៖ ពីរគ្រួសារទៀត?

ខ៖ ពីរគ្រួសារនឹង?

ក៖ ចាំ។

ខ៖ ហ្នឹងហើយមានតែប៉ុណ្ណឹងនៅតែបួននឹងទេ។

ក៖ ហើយពួកគាត់អើ....ធ្វើការងារអីគេខ្លះដែរមីង?

ខ៖ ហឺយ...!គាត់ចាស់ៗអស់ហើយនឹងក្មួយនៅមើលចៅទៅកូនទៅធ្វើការទៅអញ្ចឹងទៅ។

ក៖ ចាំ។

ខ៖ ហ្នឹងហើយមានទៅអ្នកធូរធារស្អី លំបាកដៃររស់មួយគៃៗ កូនសព្វថ្ងៃគេបានមកចិញ្ចឹមម៉ែចិញ្ចឹមកូននឹងគ្មានបានទៅធ្វើមានអីណាទេ៕

ក៖ ចុះអ្នកមីងអឹម.....ម្ដាយអ្នកមីងឈ្មោះអ្វីដែរ?

ខ៖ ឈ្មោះអ៊ុំហ៊ិន។

ក៖ ឈ្មោះអ៊ុំហ៊ិន ចុះឪពុកវិញ?

ខ៖ ឪពុកឃ្លាំងសួង។

ក៖ ឃ្លាំងសួង ហើយពួកគាត់ទាំងពីរនឹងអាយុប៉ុន្មានហើយបើឥឡូវ គិតមកឥឡូវ?

ខ៖ បើនៅមើលកាលគាត់ងាប់មើលមិនដឹង កៅ(១៩៩០)មិនដឹងប៉ែត(១៩៨០)ទេណាស់ប៉ុន្តែបើកាលគាត់ស្លាប់នឹងនៅក្នុងអាយុគាត់ណាស់..។

ក៖ ចាំ។

ខ៖ ឪពុកបានប៉ែតប្រាំ(១៩៨៥)ស្លាប់ ដល់យាយស្លាប់មុនគាត់បងអាយុគាត់បងមួយឆ្នាំប្អូនមួយឆ្នាំហ៉ាណាស់។

ក៖ ចាំ។

ខ៖ ដែលបងប្ដីបងមួយឆ្នាំប្អូនប្រពន្ធប្អូនមួយឆ្នាំ ដល់ពេលស្លាប់ប្ដីនឹងអាយុប៉ែតប្រាំ(១៩៨៥)ប្រពន្ធនឹងអាយុប៉ែត(១៩៨០)គត់ ប៉ែតគត់នឹងប្រពន្ធនឹងស្លាប់មុនប្ដី៕

ក៖ ចាំ។

ខ៖ ហ្នឹងហើយដល់ប្ដីប៉ែតប្រាំ ប៉ែតប្រាំ(១៩៨៥)។

ក៖ គាត់ស្លាប់ឆ្នាំណាដែរមីង?

ខ៖ អើ....ក្មួយហើយមីងឈឺច្រើនពេក។

ក៖ អត់ចាំទេអ្នកមីងណំា?

ខ៖ ទាល់ អត់ចាំទេណំា ក៏ទៅមើលកន្លែងម៉ុងន៎ បានដឹងថាថ្ងៃកំណើតថ្ងៃស្លាប់ផោះគាត់(របស់គាត់)នឹង បានមីងដឹង៕

ក៖ អាចប្រហាក់ប្រហែលបានទេមីងម៉ោ?

ខ៖ ចាំតិចទាល់តែបងនោះ បងផ្ទះទៀង ហុងនឹងបាន ទៀងហុងនឹងក៏មិនសូវចាំទៀតទាល់តែប្ដីគាត់ព្រោះប្ដីគាត់អ្នកសរសេរកន្លែងអក្សរនៅកន្លែងម៉ុងនឹងហាំ៕

ក៖ ចាំ។

ខ៖ ហ្នឹងចាំទាល់គាត់នឹងហើយនឹងបងទីមួយនៅអីក្រុមហ៊ុននឹងនឹងបានគាត់ចាំ។

ក៖ ចាំ។

ខ៖ បើមីងអត់កើតទេឈឺច្រើនពេកថ្លង់វង្វេងមុខវង្វេងក្រោយទេក្មួយមើលតែទូរស័ព្ទមីងមិនដឹងចេះចុចទៅគេវិញផងនឹងក្រុមហ៊ុនតេមកចុចទទួលអាឡូគេនិយាយអង់គ្លេសឯណាណោះបិទទៅទូរស័ព្ទអស់លុយទាល់លោកអ្នកអត់មានទឹកប្រាក់បានដឹងអស់លុយទៅអញ្ចឹង៕

ក៖ អញ្ចឹងអ្នកមីងអើ....ដឹងថ្ងៃខែឆ្នាំកំណើតពួកគាត់ទេ?

ខ៖ ថាមីង សួរមីងនឹងវាចប់ហើយទោះបីបងទីមួយនឹងក៏មិនស្គាល់ផង មិនដឹងផងមើលទៅបើថ្ងៃខែកំណើតរបស់គាត់កើត..។

កៈ  អញ្ចឹងឥឡូវបើអត់ចាំទេចាំថាគាត់កើតឆ្នាំអីឆ្នាំខ្មែរចន្ទគតិ?

ខៈ  គាត់ឆ្នាំខ្មែរគាត់ឆ្នាំកុរ។

កៈ  អឺ..តើ  តើម្ដាយរបស់អ្នកមីងឆ្នាំកុរ?

ខៈ  តា  តាឆ្នាំកុរ  ជូតម្ដាយ  ម្ដាយជូតឪពុកកុរ។

កៈ  ម្ដាយជូតឪពុកកុរ?

ខៈ  បងមួយឆ្នាំប្អូនមួយឆ្នាំ។

កៈ  អញ្ចឹងម្ដាយជូតឆ្នាំកណ្ដុរ?

ខៈ  កណ្ដុរ  តាជ្រូក។

កៈ  តាឆ្នាំកុរជ្រូក?

ខៈ  ជ្រូក  ជ្រូកសត្វជ្រូក  ជ្រូកនឹងកណ្ដុរ។

កៈ  ចាំ  ហើយពួកគាត់កើតនៅឯណាដែរអ្នកមីង?

ខៈ  គាត់នឹងហៃស?ពីដើមឡើយនៅកន្លែងនឹងហាំ  នឹងមីងក៏កើតមិនទាន់ដែរណាស់។

កៈ  ចាំ។

ខៈ  តែនៅគេហៅភូមិវារី។

កៈ  កន្លែង  កន្លែងនឹងគឺខេត្តកំពង់ចាមវារីកើត  ភូមិវារីកើត?

ខៈ  ខេត្តកំពង់ចាមនឹងហើយ  ពីកំណើតកើតរបស់គាត់មកណាស់គេហៅភូមិវារីចាស់  ភូមិវារីចាស់ណាស់អាហ្នឹង  ហ្នឹងហើយ។

កៈ  ភូមិវារីចាស់។

ខៈ  ដល់តែកំណើតកើតជាគាត់នៅនឹងដល់ពេលអញ្ចឹងទៅជំនាន់អិនតាំយើងនឹងហៃក។

កៈ  អ៊ុនតាក់?

ខ៖ មិនមែនអ៊ុនតាក់ទេអ៊ិនតាំ។

ក៖ អ៊ិនតាំ?

ខ៖ គេហៅអ៊ិនតាំៗជំនាន់អ៊ីសារ៉ាក់នឹងណាស់។

ក៖ អ៎រ...។

ខ៖ លោកអ៊ិនតាំ អ្នកស្រីតាបនឹង អាពេលគេដេញពីនឹងមកមីងអត់ទាន់ដឹងទេតែទាល់... ទើបដែលត្រូវហើយ..។

ក៖ ចុះឆ្នាំណាមីងអ៊ិនតាក់ អ៊ិនតាក់ អ៊ិនតាំនោះ?

ខ៖ អ៊ិនហ៊ឹម.....ថាមីងមិនដឹងថាមីងកើតមិនទាន់អ៊ីសារ៉ាក់។

ក៖ ហ៊ីសៗៗ......(សើច)

ខ៖ ថែមគេហៅម៉ាជំនាន់អ៊ីសារ៉ាក់។

ក៖ ចាំ។

ខ៖ ម៉ាជំនាន់អ៊ីសារ៉ាក់។

ក៖ មុនអាពត(ប៉ុលពត)ទៀតអញ្ចឹង?

ខ៖ មុននឹងទៀតតាំងពីជីដូន ជីដូននៃកតា តាសួងនឹងម៉ែស។

ក៖ ចាំ ព្រោះយូរហើយ។

ខ៖ ជីដូនជីទួតគាត់ទៀតណំា។

ក៖ ចាំ។

ខ៖ នឹងហើយតាំងពីម៉ាជំនាន់ថា ស៊ីកន្ទួកនឹងណាស់អត់ចេះស៊ីអង្ករថាឆ្អឹងហំា...គ្រាប់អង្ករយើងចាក់គរទៅជាដំបូកស៊ីតែកន្ទួកទេ ខ្លាចស្លាក់ក គ្រាប់អង្ករណានឹងរាមក្តេ័គាត់និយាយប្រាប់កូនៗអោយស្តាប់ហាំ។

ក៖ ចាំ។

ខ៖ ថាលូង់ហាំ ឆោតហាំ ចាស់ពីដើមយកស្វែយកកន្ទួកអង្ករមានម៉ាស៊ីនណាបុក បុកនឹងដៃទេ ទៅបន្ទាក់យកអង្ករចេញយកទៅចាក់ចោលកើតជាជំបូកជាភ្នំនាំគ្នាស៊ីកន្ទួក។

ក៖ ចាំ អញ្ចឹងជំនាន់នឹង។

ខ៖ អញ្ចឹងហាំ នឹងហើយថាស៊ីកន្ទួកទេ ខ្លាចស្លាក់ក អង្ករនឹងឆ្អឹងគ្រាប់អង្ករនឹងហាំដល់...
.ចុះអញ្ចឹងទៅគេចង់មកបង្កើតអោយមានផ្លូវមានទីវត្តអារាមហាំ។

ក៖ ចាំ។

ខ៖ ក៍ដេញពីភូមិនឹងមកអោយមកចេញមកខាងក្រៅនឹងព្រៃខ្លាព្រៃជំរឺទេកន្លែនឹងហ៊ែក៕

ក៖ តែភូមិពីរនឹងជាប់គ្នាអញ្ចឹងហាំអ្នកមីង?

ខ៖ ភូមិនៅភូមិគេហៅថាត្រពាំងបេង ត្រពាំងបេងសព្វថ្ងៃនឹងហាំ៕

ក៖ អំរ..... ត្រពាំងបេងសព្វថ្ងៃនឹងវារីចាស់ពីមុន?

ខ៖ ភូមិគេហៅភូមិរី។

ក៖ ភូមិរី?

ខ៖ ភូមិ ភូមិវារីចាស់នឹងមានតែនៅមួយទួលទេ។

ក៖ ចាំ។

ខ៖ មួយទួលនឹងវាធំដែរហើយក្រៅពីនឹងសុទ្ធតែដីស្រែទេណាស់ ស្រែពទ្ធ័ជុំវិញអញ្ចឹងទៅដូចថាព្រៃកោះអញ្ចឹងហាំ។

ក៖ ចាំ។

ខ៖ ហ្នឹងហើយ។

ក៖ អញ្ចឹងយាយគាត់កើតនៅនឹង?

ខ៖ កើតនៅនឹងយាយតាម្តាយជីដូនអីនៅនឹងទេ។

ក៖ ចាំ។

ខ៖ នៅនឹងទេ។

ក៖ អញ្ចឹងមានន័យថាពួកគាត់នៅកំពង់ចាមតាំងពីជំនាន់ចាស់ពីដើម?

ខ៖ នៅ....នឹងហើយគេហៅចំការលើ ចំការលើណា។

ក៖ ចាំ។

ខ៖ ចំការលើស្វាយទាបបានគេបង្កើតថាខេត្តកំពង់ចាម ស្រុកចំការលើ ឃុំស្វាយទាប។

ក៖ ចាំ។

ខ៖ គេដេញអោយយើងកាប់ដីកាប់ធ្លីចាប់កាប់ព្រៃយកទៅ អ្នកណាកាប់បានប៉ុន្មានយកបានប៉ុណ្ណឹងទៅណាស់៕

ក៖ ចាំ។

ខ៖ ថាព្រៃឈើប៉ប៉ុនៗធំជាងកង់រទេះទៀតហើយដែរថាអ្នករស់នៅនឹងហាំ អ្នករស់នៅនឹងហាំជ្រុះសក់អស់ហើយក្ងួយ។

ក៖ ម៉េចអញ្ចឹង?

ខ៖ ដែលឈឺវាចាញ់ហាំ។

ក៖ អំរ.....។

ខ៖ វាចាញ់។

ក៖ ចាំ។

ខ៖ ព្រៃខ្លាព្រៃដំរី អ្នក។

ក៖ នៅម្តុំផ្ទះ។

ខ៖ នឹងៗនែក កន្លែងនឹងនែក ដែលបង្កើតភូមិវាស់ថ្នល់វាស់វែងកើតជាផ្ទះកើតជាវត្ត កើតជាថ្នល់ជាតិនឹងដីនឹងហើយដែលមកកាប់ព្រៃចេញពីនឹងមកនោះ៕

ក៖ ចាំ។

ខ៖ កាប់ព្រៃបានហើយបានរើផ្ទះមកនៅ។

ក៖ ចាំ។

ខ៖ ហ៊ឺ...ហ្នឹងអញ្ចឹង។

ក៖ ចាំ។

ខ៖ អានឹងដែលតាគាត់និយាយអីយើងកើតមកទាន់ម្ដាយឪពុកយើងនឹងណាស់ ដែលចំណែកម្ដាយខាងម៉ែយើងម្ដាយយាយហ៊ិននឹងហាំ យាយយើងនឹងយើងអត់ទាន់ទេ ទាន់តែម្ដាយខាងឪពុកទេ ម្ដាយខាងយាយនឹងស្លាប់ចោលគាត់ បងប្អូនបីនាក់នឹងតាំងពីតូចៗម៉ែស(ម៉្លេះ)គាត់នៅជាមួយម្ដាយធំគាត់ទេ បងម៉ែគាត់ទេ៕

ក៖ ចាំ។

ខ៖ នឹងហើយគាត់នៅតូចៗបងគាត់ប្រុសពីនាក់គាត់ពៅគេស្រីមួយប្រុសពីរនឹងនៅជាមួយម្ដាយធំទេនែក.....ម៉ែឈ្មោះយាយហ៊ិននឹងហាំម្ដាយគាត់នឹងគាត់មិនដឹងស្គាល់មុខម្ដាយគាត់ម៉េចផងនៅជាមួយម្ដាយធំទេ៕

ក៖ ចាំ។

ខ៖ ប្រវត្តិគាត់កំសត់ណាស់គ្មានទេ។

ក៖ ចុះអើ....ឪពុករបស់អ្នកមីងធ្វើការងារអ្វីដែរសំរាប់ចិញ្ចឹមជិវិត?

ខ៖ គាត់អាជីពគាត់មានតែស្រែចំការទេក្មួយអើយ។

ក៖ អញ្ចឹងគាត់ស្រែចំការហ៎...?

ខ៖ ធ្វើស្រែចំការទេ។

ក៖ គាត់ជាមនុស្សបែបម៉េចដែរ?

ខ៖ អ្វូ...ៗគាត់ គាត់មានទៅស្អីគាត់ គាត់អ្នកធ្វើស្រែធ្វើចំការជិវិតកម្មករដែរនឹង។

ក៖ ចាំ។

ខ៖  គាត់មានទៅអ្នកកាប់ចាក់ផឹកស៊ីឯណាគាត់មិនចេះទេ  គាត់ព្រោះគាត់អ្នកបួស  គាត់បួសនៅកាលមួយជំនាន់ពីសង្គមមើលគាត់បួសតាំងពីអាយុបីដណ្ដប់គាត់ទៅនៅវត្តលោកអាយុពីដណ្ដប់ហាំ។

ក៖  ចាំ។

ខ៖  ទៅរៀនទៅសូត្រនៅតាមវត្ត  ដល់តែពេលគាត់សករាជ  គេហៅថាសករាជៗនឹងមក លេងនឹងសករាជនៅនឹងវត្តស៊ឹងយើងនឹងនែក  ទៅក៏ឃើញគាត់នឹង  សុំគាត់នឹងទៅនៅព្រះវិហាជាមួយ។

ក៖  ចាំ។

ខ៖  ទៅនៅប្រាសាទព្រះវិហារហាំ។

ក៖  អរ....។

ខ៖  ប្រាសាទព្រះវិហារដែលកប៉ាល់ហោះទម្លាក់គ្រាប់បែកនឹងគាត់នៅបួសនៅនឹងហាំណាស់។

ក៖  ចាំ។

ខ៖  នៅបួសនៅនឹងទេ។

ក៖  ចាំ។

ខ៖  ស្របក់ម្ដាយគាត់។

ក៖  កាលនឹងគាត់ប្រហែលជាអាយុប៉ុន្មាន?

ខ៖  គាត់  មើលរាប់គ្រប់អាយុហើយអាយុប្រាំមួយដណ្ដប់(អាយុ១៦)  ប្រាំពិលដណ្ដប់(១៧) ហើយគាត់បួសភឹក្សហើយនឹង៕

ក៖  ចាំ។

ខ៖  នៅនឹងបួសភឹក្សហាំរួចទៅកប៉ាល់ហោះទម្លាក់គ្រាប់បែក  ម៉ាជំនាន់នឹងមានឡានណាចេញចូលមានតែឡានបារាំងដឹកឈើទេគាត់និយាយហាំ..។

ក៖ ចាំ។

ខ៖ គ្មានអីមកទេ ម៉ែគាត់យំរីងរៃ គាត់នៅកន្លែងអាប្រាសាទកប៉ាល់ហោះទម្លាក់គ្រាប់បែកនឹង នៅអាប្រាសាទព្រះវិហារនឹងហាំ។

ក៖ ចាំ។

ខ៖ កន្លែងគេធ្វើជំរឿនទាហាននឹង។

ក៖ ចាំ។

ខ៖ គេបញ្ជាំងមកនឹងហាំគាត់និយាយថាអ៊ឺ...កូនអើយទៅនៅនឹងពេលថាចាំទាល់មើល អោយតែពេលគេរៀបចំស្រុកស្រួលបួលនាំកូននាំបងទៅលេងកន្លែងគាត់បំបួសនៅនឹងនៅខ្វងក្សាន្ត។

ក៖ ក្សាន្ត?

ខ៖ ខ្វង វត្តខ្វងក្សាន្ត។

ក៖ វត្តខ្វងក្សាន្ត?

ខ៖ អើ...!នៅខាងព្រះវិហារនឹងហាំ។

ក៖ ចាំ។

ខ៖ ប្រាសាទព្រះវិហារស្អីកោះក្របីកោះអីនឹងហាំកន្លែងគាត់បួសនឹងហាំ។

ក៖ ចាំ។

ខ៖ កន្លែងគាត់នៅហើយនឹងហាំ។

ក៖ ចុះម្ដាយអ្នកមីងគាត់ធ្វើអ្វីដែរកាលនឹង?

ខ៖ អឹម....គាត់នៅធ្វើស្រែធ្វើអី កាលនឹងគាត់មើលតែកូនៗនឹងកូនច្រើន ប្ដីធ្វើចំការធ្វើស្រែទៅ៕

ក៖ ចាំ។

ខ៖ គាត់មានធ្វើអីគាត់ អត់មាន។

ក៖ អញ្ចឹងគាត់ជាមនុស្សបែបម៉េចដែរ?

ខ៖ អូ......!គាត់អ្នកតាំងពីថាចាប់ដៃប្តីប្រពន្ធមកមិនដែលចិញ្ចឹមមាន់មួយ មិនដែលសំលាប់សត្វមិនដែលអីទេ៕

ក៖ ចាំ។

ខ៖ គាត់ គាត់ថាដាក់បាត្រលោកតាំងពីអាយុសាមគត់ទល់ៗនឹងស្លាប់ គាត់មិនដែលសំលាប់មាន់ ចិញ្ចឹមមាន់ចិញ្ចឹមជ្រូកមួយទេក្មួយ នឹងគាត់និយាយប្រាប់ណាស់៕

ក៖ ចាំ តែគាត់ធ្វើស្រែចំការដែរ។

ខ៖ ធ្វើស្រែចំការទេ។

ក៖ ចាំ។

ខ៖ ដល់មកជំនាន់នឹងដីយើងមាន
 អីមានណាស់ ដល់មកដីសុទ្ធតែចែកអោយកូនអស់ ដល់មកជំនាន់ដាច់នេះគេយករបស់កម្មសិទ្ធិនឹងដាក់ជារួមទៅ ចែកទៅកន្លែងនេះមិនប៉ុន្មានម៉ែត្រ ទីនោះប៉ុន្មានម៉ែត្រនរណាកូនច្រើនទៅបានច្រើនទៅ

អ្នកណាកូនតិចបានតិចទៅកន្លែងនេះបីបួនម៉ែត្រម្នាក់ទៅអីអញ្ចឹងទៅ បត់តែនង្គ័លបត់មិនកើតផងនឹងគាត់ជួលអោយទៅគេអស់គាត់ចាស់ហើយមានអីណាមានគោមានពពែណាទៅភ្ជួរណាកើតទៀតបើគាត់ចាស់ហើយហាំ....ជួលអោយគេយកស្រូវហូបទៅ៕

ក៖ ចាំ ចុះអ្នកមីងបានចាំអ្វីខ្លះអំពីឪពុកម្តាយអ្នកមីងកាលពីជំនាន់នោះ?

ខ៖ មីងដឹងក្តីមកមួយជំនាន់នោះគាត់មានអីគាត់ដូចថាចំការគាត់មាន ស្រែអញ្ចឹងទៅគាត់លែងធ្វើភ្ជួរស្រែខ្លួនឯងអីអញ្ចឹងអាយុប៉ុននេះគាត់ឆ្ការបុសចេកគាត់អីមានណាស់បួនដប់ហាត់អីអញ្ចឹងទៅ៕

ក៖ ចាំ។

ខ៖ ដីដាំកប្បាស ដាំសណ្តែកបូនដប់ហាត្ថអញ្ចឹងទៅ ដល់...!អញ្ចឹងទៅគាត់រកស៊ីជួញចេក ។

ក៖ ចាំ។

ខ៖ ជួញចេកដាក់ទៅស្វាយរៀងទៅស្វាយរៀងមួយកន្លែងទៅ ភ្នំពេញមួយកន្លែងទៅ តាកែវមួយកន្លែងទៅដាក់ចេកមួយសារ១ទៅបីនឹង។

ក៖ ចាំ។

ខ៖ ប៉ុន្តែឡានប៉ារគេទេ។

ក៖ ចាំអ្នកមីង។

ខ៖ ឡានដឹកទៅនោះ។

ក៖ គាត់?

ខ៖ ពីយប់បីយប់មកដល់វិញហើយយកទៅបោះអោយគេនឹងណាស់។

ក៖ អញ្ចឹង អញ្ចឹងគាត់ធ្វើចំការផងគាត់រកស៊ីផង?

ខ៖ នឹងហើយគាត់គ្មានទៅនេះជំនួញអីស៊ីផឹកអីទេ គាត់មិនចេះទេព្រោះគាត់អ្នកបួសអ្នករៀន។

ក៖ ចាំ។

ខ៖ គាត់រកអញ្ចឹងរកតាមកំលាំងសាមញ្ញទឹកញើសគាត់ទេ។

ក៖ ចុះគាត់ដែលធ្លាប់ប្រាប់អ្នកមីងពីជីវប្រវត្តិគាត់ សាច់រឿងគាត់អោយអ្នកមីងបានដឹងខ្លះទេ?

ខ៖ នឹងដូចថាមីងធ្លាប់ដឹង១ក្តីមកគាត់និយាយអញ្ចឹងគាត់ ហើយមីងក៏ទាន់ដែរមកត្រឹមថាអារឿងគាត់ផឹកស៊ីអីគាត់គ្មានទេ ទៅគាត់មានតែមុខរបរស្រែចំការគាត់នឹង ដល់ដីគាត់ច្រើនហាំគាត់ជួលអោយគេ។

ក៖ ចាំ។

ខ៖ ជួលអោយគេមួយឆ្នាំៗបីរយថាំងអីអញ្ចឹងទៅហ្វូបអត់អស់ទេ ជង្រុកនឹងធ្វើដូចផ្ទះនៅចឹង៕

ក៖ បីរយថាំងប្រហែលជាប៉ុន្មានលុយឥឡូវនឹងអ្នកមីង?

ខ៖ អូ.......!មីងមិនដឹងគេលក់មួយតៅប៉ុន្មានទេក្មួយអើយម៉ាជំនាន់នឹង អង្ករម៉ាជំនាន់ណឹងគេអត់លក់ថ្លឹងគីឡូទេ គេវាល់តៅមួយតៅពីដណ្តប់គីឡូ(១២គីឡូ)។

ក៖ ចាំ។

ខ៖ មួយតៅពីដណ្តប់គីឡូ(១២គីឡូ)មីងដឹងតែប៉ុណ្ណឹងទេ អារឿងហាងឆេងចុះឡើងទេរឿងស្រូវនោះ។

ក៖ ចាំ។

ខ៖ នឹងហើយស្រែជួលអោយគេទៅដល់ខែមកចាំតែប្រមូលផលដាក់ជង្រុកទៅហ្វូបមួយឆ្នាំៗហ្វូបអត់អស់ទេស្រូវហ៎៕

ក៖ ដឹងតែថាជំនាន់នឹងសំបូរអីហ្វូប។

ខ៖ អូ......សំបូរដី។

ក៖ អត់ខ្វះ។

ខ៖ កូនចែកអោយមានគ្រប់គ្នាពីហត្ថៗ កូនបងអញ្ចឹងដែរការហើយចែកចំការធ្វើផ្ទះអីអោយ មានលុយមានកាក់អីចែក។

ក៖ ចាំ។

ខ៖ អឺ.....មកត្រឹមមីង មកត្រឹមបងទីប្រាំមួយនឹងមើលទីប្រាំមួយយើង យើងនិយាយតាំងពីអាអ្នកងាប់អីទាំងអស់ណា។

ក៖ ចាំ។

ខ៖ ទៀង ហុងនឹងទីប្រាំមួយ។

ក៖ ចាំ។

ខ៖   ទីប្រាំមួយត្រឹមនឹង។

ក៖   ចាំអ្នកមីង   អញ្ចឹងអ្នកមីងមានបានចាំពីរឈ្មោះជីដូនជីតាអត់?

ខ៖   គ្រាន់តែចាំតែឈ្មោះតែអត់ស្គាល់មុខ។

ក៖   អត់ស្គាល់មុខគាត់   ជីហុី.ៗៗៗៗៗ(សើច)។

ខ៖   អត់ស្គាល់មុខហែសៗៗៗៗៗៗៗ(សើច)។

ក៖   អញ្ចឹងជីដូនឈ្មោះអី   ជីតាឈ្មោះអីដែរអ្នកមីង?

ខ៖   ព្រោះ...!ជី   ជីតាខាងម៉ែឈ្មោះអុំខែ.......តាអុំ។

ក៖   តាអុំ។

ខ៖   ត្រកូលគាត់ឈ្មោះត្រកូលគាត់អត់   មីងអត់ដឹង   ដឹងថាតាអុំតែម្ដង   ដឹងតែម៉ែអុំហុិន អញ្ចឹងតាម៉ង(តែម្ដង)។

ក៖   ចាំ។

ខ៖   ហើយនឹងឪពុកខាងឪពុក   ឪពុកគាត់តាទៀង។

ក៖   តាទៀង។

ខ៖   តាទៀងរួចឪតាទៀងឈ្មោះតាឃ្លាំង។

ក៖   តាឃ្លាំង?

ខ៖   តាឃ្លាំង។

ក៖   ចាំ។

ខ៖   នឹងអញ្ចឹង   ដល់ម្ដាយឈ្មោះយាយរិច   ប៉ុនមិនដឹងត្រកូលគាត់ស្អីទេម្ដាយខាងឪពុកហាំ ណាស់។

ក៖   ចាំ។

ខ៖ ទាន់គាត់ប៉ុន្តែមិនដឹងគាត់ឈ្មោះយាយវិចៗអញ្ចឹងតាម៉ង(តែម្តង)ដល់ត្រកូលគាត់មីងអត់ស្គាល់ទេ៕

ក៖ អញ្ចឹងអ្នកមីងចាំថ្ងៃខែឆ្នាំកំណើតពួកគាត់ទេ? ហ៊ុសៗៗ.....(សើច)

ខ៖ ហ៊ឺ....!ម្តាយអើយអត់ចាំទេ។

ក៖ អញ្ចឹងអ្នកមីងចាំទីកន្លែងកំណើតពួកគាត់ទេ?

ខ៖ នឹងហើយ ដូចមីងនិយាយខាងដើមអញ្ចឹងកំណើតកើតជាពីនៅភូមិវារីចាស់នឹងគេហៅភូមិវារី វារីចាស់ហ៎ណាស់។

ក៖ ភូមិវារីចាស់? ចា៎។

ខ៖ នឹងហើយពីកំណើតពីជីដូនពីជីលួតមកនឹង។

ក៖ ភូមិវារីចាស់ជំនាន់នឹងស្រុកអីគេអ្នកមីង?

ខ៖ អាហ្នឹងមីងអត់ដឹងស្រុកដឹងគេដាក់ស្រុកអីគេទេកាលមួយជំនាន់នឹង។

ក៖ ចំការលើនែក?

ខ៖ ចំការលើដែរហើយ។

ក៖ គេជំនាន់នឹងគេដាក់ឈ្មោះចំការលើហើយ។

ខ៖ នឹងហើយដាក់ចំការលើអញ្ចឹងហើយព្រោះអីវាខេត្តកំពង់ចាមដែរ កំពង់ចាមដូចគ្នា។

ក៖ ចា៎។

ខ៖ អញ្ចឹងគេភូមិវារីចាស់នឹងហើយខេត្តកំពង់ចាមដែរ។

ក៖ ចុះអ្នកមីងដឹងពីប្រវត្តិ ជីវប្រវត្តិជីដូនជីតាអ្នកមីងខ្លះៗទេអាចប្រាប់បាន?

ខ៖ ហ៎.....មីងបើមីងមិនដឹងកើតទាន់ឃើញមុខគាត់ផងក្មួយអើយ។

ក៖ ក្រែងលោថាអ្នកមីងគាត់ធ្លាប់លឺអីអញ្ចឹងហ៎ណាស់តៗគ្នាអីអញ្ចឹងទៅណាស់។

ខ៖ អត់ អត់ទេអត់ដែលទេ។

ក៖ ចាំ។

ខ៖ ដឹងតែពីឪពុកនឹងមានអីទេ ក្មួយអើយបើជំនាន់នឹងធ្វើតែស្រែតែចំការគ្មានទៅមានអី។

ក៖ អញ្ចឹង
 អញ្ចឹងមានន័យថាក្រុមគ្រួសារអ្នកមីងទាំងអស់គ្នាតាំងពីជីដូនជីតាមកគឺរស់នៅក្នុងខេត្តកំពង់ចាម?

ខ៖ នឹងហើយនៅនឹង។

ក៖ អញ្ចឹងរយៈពេលយូរប្រហែលប៉ុន្មានហើយ?

ខ៖ គិតទៅមើលគាត់ចេញមកមើលគាត់ចេញពី...ពីភូមិវារីចាស់មក មកកាប់ព្រៃហើយនឹងមកលើកផ្ទះ ផ្ទះគាត់ហ៎ណាស់ដែលកាប់ព្រៃនឹងមកលើកណាស់ពុកហ៎ណាស់។

ក៖ ចាំ។

ខ៖ ក្នុងឆ្នាំមមែកំណើតទៀងហុងនឹងមកកើតនៅលើផ្ទះនឹងតែម៉ង។

ក៖ គាត់កើតឆ្នាំណា?

ខ៖ ធ្វើហើយកើតតែម្តងក្នុងឆ្នាំមមែហុកជាង(១៩៦០ជាង)ហ៎ណា។

ក៖ ចាំ។

ខ៖ ប្រាំមួយរយ ប្រាំមួយរយហុកប្រាំបីហ៎ណាដែលដាក់ផ្លាកផ្ទះនឹង។

ក៖ អ៎រ....។

ខ៖ ពីដើមគេមិនដាក់អាលេខផ្ទះយើង ដាក់បង់លេខកំណើតឆ្នាំហ៎ណាស់។

ក៖ ចាំ។

ខ៖ ដូចជាប្រាំមួយរយហុកប្រាំបី(៦៦៨)នឹងអញ្ចឹងហើយ។

ក៖ នឹងឆ្នាំៗហ៎......?

ខ៖ កំណើតកើតគាត់ឆ្នាំមមែ។

កៈ  ឆ្នាំខ្មែរណាំ។

ខៈ  អើ..ឆ្នាំខ្មែរនឹងឆ្នាំមមែ។

កៈ  ឆ្នាំបារាំងឆ្នាំណាដែរអត់ចាំទេណាំ?

ខៈ  សួរមីង  មីងអត់ចាំទេមីងគ្រប់អាយុឡើងជំនាន់អាពតតាម៉ង(តែម្តង)នឹង។

កៈ  ចាំ។

ខៈ  អាយុប្រាំបួនឆ្នាំមីងនៅក្នុងអាពត(ប៉ុលពត)ទេណាស់។

កៈ  ចាំអ្នកមីង។

ខៈ  ហាំ....!ប្រាំបួនឆ្នាំអី  អញ្ចឹងហើយប្រាំបួនឆ្នាំ។

កៈ  ប្រាំបួនឆ្នាំនៅក្នុងអាពត(ប៉ុលពត)។

ខៈ  ហ៊ឹម....។

កៈ  អញ្ចឹងអ្នកមីងមានសាច់ញាត្តិបងប្អូនណាអ្នកមីងរស់នៅក្រៅប្រទេសអត់?

ខៈ  ឳ....គ្មានទេក្មួយអើយពូជគ្មានពីណាបានមួយទៅក្រៅអីទេ។

កៈ  ចុះអ្នកមីងតើស្វាមីឬប្តីអ្នកមីងមានឈ្មោះអ្វីដែរ?

ខៈ  ឈ្មោះ  ហេងស៊ីថា។

កៈ  ឈ្មោះហេងស៊ីថា  អ្នកមីងរៀបអាពាហ៍ពិពាហ៍នៅពេលណាដែរឆ្នាំណា?

ខៈ  នៅក្នុងជំនាន់អាពត(ប៉ុលពត)ចុង
ចុងខែដាច់    ដាច់អាពតនឹងតែម៉ងរៀបបានកន្លះខែដាច់ដឹងតែរៀបបានកន្លះខែដាច់អញ្ចឹងតែម្តង៕

កៈ  អញ្ចឹងប្រហែលជានៅក្នុងឆ្នាំចិតប្រាំហាំអ្នកមីងមួយពាន់ប្រាំបួនរយចិតប្រាំណាំអ្នកមីងណាំ?

ខៈ  អឺម..។

ក៖ ចិតបួនហ៎?

ខ៖ យើងដាច់ ដាច់អាពត(ប៉ុលពត)នឹងយើងសង្គ្រោះបានប៉ុន្មាន។

ក៖ ឆ្នាំចិតប្រាំ(១៩៧៥)។

ខ៖ ចិតប្រាំ ចិតប្រាំហ៎។

ក៖ ចា៎។

ខ៖ អើ។

ក៖ អញ្ចឹងចិតបួន ចិតប្រាំនឹងណ៎អ្នកមីងណ៎?

ខ៖ មីងរៀបបានតែកន្លះខែដាច់។

ក៖ អរ......អញ្ចឹងក្នុងឆ្នាំចិតប្រាំតែម្ដង។

ខ៖ អើនឹងហ៎។

ក៖ ហើយ....អឺ..ការរៀបអាពាហ៍ពិពាហ៍នឹងរៀប រៀបអាពាហ៍ពិពាហ៍នឹងម៉េចដែរអ្នកមីង?

ខ៖ អឹម.....!ក្មួយអើយក្មួយមួយជំនាន់មីងចុងគេហើយណាស់កាលពីគេការមុនយើងមកនិយាយមកត្រឹមមីងចុះអត់មានអ្នកកំដរទេហើយគ្មានបាយក្នុងផ្ទះអីទេពេលម៉ោងប្រាំពិល(ម៉ោង៧)ទៅជួបជុំគ្នាអញ្ចឹងទៅស្លៀកខ្មៅពាក់ខ្មៅទៅ ក្រម៉ាគេចែកអោយ

អញ្ចឹងទៅណាស់របស់គេចែកអោយអំបោះទៅ ទៅប្ដេជ្ញាចិត្តទៅគេថាធ្វើការគេអោយយើងប្ដេជ្ញាចិត្តក្នុងមួយឆ្នាំក្នុងមួយហាត់ធ្វើអោយបានផលប៉ុន្មានតោនអញ្ចឹងហ៎គេអោយយើងប្ដេជ្ញាចិត្តហ៎។

ក៖ ចា៎។

ខ៖ អើ....រួចក្នុងមួយហាត់វាបានបីតោនហ៊ែស ជួនកាលបានតែពីតោនអីទេអញ្ចឹងហើយប្ដេជ្ញាចិត្តយើងតស៊ូអោយអស់ពីសម្ថភាព សម្ថភាពនឹងដើម្បីបីតោនទៅបួនតោនគេអោយប្ដេជ្ញាចិត្តអញ្ចឹងហ៎ជំនាន់អាពត(ប៉ុលពត)ណាស់៕

ក៖ ចា៎។

ខ៖ អឺ.... អោយប្តេជ្ញាចិត្តអញ្ចឹងប្តេជ្ញាចិត្តរួចហើយដល់ពេលម៉ោងបួនត្រូវជួបជុំគ្នានៅរោងបាយធំ រោងបាយរួមហ៎ណាស់។

ក៖ ចា៎។

ខ៖ ដែលហូបរួមទៅប្តេជ្ញាចិត្តនឹងទៅមានតែម៉ែឪនឹងសមីខ្លួនទេ។

ក៖ ចា៎។

ខ៖ គ្មានដាំគ្មានបាយគ្មានអង្ករក្នុងផ្ទះទេអ្នកណាហ៊ានមានតែអង្ករមួយកំប៉ុងនឹងវាយចោល(សំលាប់ចោល)ហើយក្មួយ។

ក៖ ចា៎អ្នកមីង។

ខ៖ សូម្បីតែកម្មសិទ្ធិយើងចាប់ដីថ្មីគេចែកអោយមួយផ្ទះៗដាំជំឡូងដាំអំពៅអីបាននឹង គេមិនអោយយើងកម្មសិទ្ធិទៀតយកទៅដាក់នៅរោងបាយរួម។

ក៖ ចា៎។

ខ៖ អ្នកណាក្បត់គេឃើញតែផ្សែងភ្លើងដឹងតែស្លាប់ហើយក្មួយ។

ក៖ គេយកទៅវាយចោល(សំលាប់ចោល)។

ខ៖ យកទៅវៃចោល(សំលាប់ចោល)ហើយដែលកម្មសិទ្ធិយើងដាំនៅប្លង់ផ្ទះនឹងណាស់។

ក៖ ចា៎។

ខ៖ តែជំឡូងមួយដុំអោយតែគេទាន់ដឹងតែស្លាប់ហើយ។

ក៖ ទោះជាយើងដាំក៏ដោយក៏យើងអត់អាចហូបបានដែរ។

ខ៖ ដាំខ្លួនឯងដីខ្លួនឯងមើលថែនឹងហើយបានផលយកទៅដាក់នៅកន្លែងរួមឆ្នាំងបាយធំចង្ក្រានធំ។

ក៖ ចា៎។

ខ៖ ពេលហូបគេវៃជួងម៉ឹងៗក្មេងប៉ប៉ុននេះទៅមិនទាន់នៅតែទឹកបបរទេក្មួយ មីងហ៎នៅកងចល័នៅក្នុងកងចល័តនៅនារីណាស់ក្នុងមួយខ្ទះត្នោតណាក្មួយអង្ករតែមួយកំប៉ុងទេចេកយើ

ងនឹងចេកខ្ចីយើងនឹងណាស់ស្ងោ ទៅបកទៅឈូសទៅដាក់ជាមួយ ហើយជាមួយនឹងស្លឹកបាស ដើមចេក បបរដាក់តែអំបិលទេក្មួយ ម្ហូបដើមចេកជ្រក់។

ក៖ អរ.....។

ខ៖ ដើម បបរសនឹងណាស់។

ក៖ ចាំអ្នកមីង។

ខ៖ ដើមចេកជ្រក់ បើដាំបាយវិញបាយជ្រូកជាគ្នាបាយជ្រូកក្មួយដួសមកហាំ អង្ករមួយចេកដប់ អាហ្នឹងអញ្ចឹងហើយ សម្លរក្នុងមួយខ្ទះដាក់ដួសទៅមួយក្រុមៗទៅមួយក្រុមពីរតណ្តាប់នាក់(១២នាក់)ក្នុងមួយក្រុមណាស់។

ក៖ ចាំ។

ខ៖ អើមួយក្រុមពីតណ្តាប់នាក់(១២នាក់)នឹងសម្លរមួយកាធុនប៉ុណ្ណឹងទៅបាយបានមួយចានប៉ុណ្ណឹងវាល់ដូចវាល់ចែកអោយមួយចានប៉ុនៗគ្នានឹងអញ្ចឹង។

ក៖ បាយនឹងចានប៉ុនកូនចានហាំ។

ខ៖ របបប៉ុនៗនឹងទេក្មួយ។

ក៖ ចាំ។

ខ៖ រួចទៅទឹកសម្លរនឹងមួយកាធុននឹងហូបគ្នាសាច់បានបីដុំទេក្មួយសុទ្ធតែខ្លាញ់ជ្រូកអណ្តែតក្មួយ។

ក៖ ចាំ។

ខ៖ មួយជំនាន់នឹងហាំ។

ក៖ ចុះអ្នកមីងអើ..អាពាហ៍ពិពាហ៍នឹងរៀបចំដោយឪពុកម្តាយឬក៍អ្នកមីងយ៉ាងម៉េចដែរ?

ខ៖ អានេះយើងនៅក្នុងបន្ទុកម្តាយចូលតាមផ្លូវទៅតាមច្បាប់។

ក៖ ចាំ។

ខ៖ បើអ្នកនៅក្នុងដូចថាចូលជួរក្នុងគេហៅថាក្នុងអាពត(ប៉ុលពត)អញ្ចឹងហាំ។

កៈ  ចាំ។

ខៈ  ក្នុងជួរនៅក្នុងជួរអ្នកប្តេជ្ញាចិត្តនៅក្នុងជួរតែម៉ងអត់នៅក្នុងបន្ទុកម្តាយទេអាហ្នឹងអង្គការគេរៀបអោយ។

កៈ  អញ្ជឹងអ្នកមីងនៅក្នុងបន្ទុកម្តាយឬក៏អត់?

ខៈ  នៅក្នុងបន្ទុកម្តាយទេមីងនៅក្នុងកងចល័ត។

កៈ  អញ្ជឹងម្តាយជាអ្នកទុកដាក់អោយ?

ខៈ  ទុកដាក់។

កៈ  មិនមែនអ្នកមីងស្គាល់គ្នាមុនទាក់ទងគ្នាមុនអីអត់ទេ?

ខៈ  អត់ទេអ្វី.....មួយជំនាន់នោះក្មួយ   បើអាហ្នឹងគេមិនមែនហៅថាស្នេហាទេណា។

កៈ  ចាំ។

ខៈ  គេហៅសីលធម៌  សីលធម៌ដែលស្រលាញ់លួចលាក់គ្នាសីលធម៌មួយជំនាន់នឹងគេហៅអញ្ជឹងជំនាន់អាពត(ប៉ុលពត)ហាំ។

កៈ  ចាំ។

ខៈ  គេហៅសីលធម៌នឹង  តែគេទាន់ហាំក្មួយគេរុំនឹងដែកហាំដាក់ផ្គោបលើក្រោមអញ្ជឹងគេរុំដែកដុតទាំងរស់ក្មួយ។

កៈ  អំរ....។

ខៈ  សាហាវណាស់ក្មួយ។

កៈ  អត់អោយស្រលាញ់គ្នាទៀត?

ខៈ  អត់អោយនេះ  អាហ្នឹងគេហៅថាសីលធម៌  សីលធម៌ប្រុស  ស្រីប្រុសនឹងអត់បានទេ។

កៈ  ចាំ។

ខៈ  បើយើងសព្វថ្ងៃគេហៅស្នេហាជំនាន់នឹងគេហៅសីលធម៌។

ក៖   ចុះដល់ពេលជំនាន់នឹងដល់ពេលឪពុកម្ដាយអ្នកមីងរៀបចំអោយអញ្ចឹងនែកអ្នកមីង?

ខ៖   នឹងហើយរៀបចំអោយទេ។

ក៖   អញ្ចឹងនៅក្នុង   ក្នុងពេលអត់ទាន់ជិតដាច់អាពត(ប៉ុលពត)   ប៉ុន្តែវាអត់ទាន់ដាច់អាពតទេ។

ខ៖   នៅទេរៀបបាន      ដឹងតែរៀបបានកន្លះខែមីងដាច់អាពត(ប៉ុលពត)តែម្ដង។

ក៖   អញ្ចឹងមានន័យថានៅក្នុងជំនាន់អាពតនឹងអញ្ចឹងអាពតគេអនុញ្ញាត្តិអោយមីងរៀបការឬក៏តាមឪពុកម្ដាយដែរ?

ខ៖   ហ៊ឹម....!នឹងហើយយើងនៅក្នុងគ្រួសារនៅអត់ទាន់ថាដូចថាយើងអ្នកប្ដេជ្ញាចិត្តនៅក្នុងជួរ   អាហ្នឹងគេហៅនៅក្នុងជួរ។

ក៖   ចាំ។

ខ៖   ដែលយើងនៅក្រៅបន្ទុកម៉ែឪហើយណាស់   ដែលយើងនៅក្នុងជួរ   នៅក្នុងជួរនឹងអង្គការគេ   គេរៀបចំទុកអោយ។

ក៖   អ្នកចាត់ចែង?

ខ៖   បុរសណាគេផ្គូរផ្គងអោយត្រូវតែយកបើមិនយកសំលាប់ចោល។

ក.អ៎រ....។

ខ៖   នឹងអញ្ចឹង។

ក៖   នឹង..   នឹងបើសិនជានៅ   នៅក្នុងជួរហើយអាពតជាអ្នករៀបចំអោយ?

ខ៖   នឹងហើយ   នឹងហើយ។

ក៖   យើងអត់ធ្វើតាមទេ   គេសំលាប់ចោល។

ខ៖   សំលាប់ចោលទៀតយើងសក្តិភូមិគេហៅសក្តិភូមិមួយជំនាន់នឹងដូចថាយើង   នែកអ៊ឺម.....វើសវណ្ណះគេហៅថាសក្តិភូមិ។

ក៖   ចាំ។

ខ៖  អាហ្នឹងអញ្ចឹងដូចថាអ្នកមានអ្នកក្រអ្នក  អ្នកស្អាតយកអ្នកអាក្រក់  អ្នកសយកអ្នកខ្មៅអញ្ចឹងហា៎។

ក៖  ចា៎។

ខ៖  ដូចថាយើងមិនពេញចិត្តគេថាយើងរើសវណ្ណៈកូនសក្តិភូមិនាយទុន  នឹងរបបនៅរើសវណ្ណៈជិះជាន់គេហើយណា។

ក៖  ចា៎។

ខ៖  វាយចោល(សំលាប់ចោល)ហើយ។

ក៖  សំលាប់ចោល?

ខ៖  សំលាប់ចោលហើយក្មួយបើមិន  មិនសំលាប់ចោលនឹងគ្រាប់កាំភ្លើងអីទេណាស់កាំបិត។

ក៖  អ៊ូយកាត់ករម៉េង?

ខ៖  បើមិនអញ្ចឹងទេខ្នងពូថៅ។

ក៖  ខ្នងពូថៅយកមកសំពង។

ខ៖  ខ្នងពូថៅកាប់ដំក្បាលយើងហើយណាស់  កាប់ភូសអញ្ចឹងទៅណាស់  ជំនាន់បងទីពីរនឹងស្លាប់  នៅអ្នកចិតប្រាំ(១៩៧៥)ដែលមីងនិយាយថាធ្វើការនៅប៉ូជិនតុងនឹងងាប់នឹងស្វាយចន្ទីនេះគេកាប់រណ្តៅរួចស្រេចឆ្កកដាក់រទេះទៅ។

ក៖  ចា៎។

ខ៖  ឆ្កកទៅយោធាគេអង្គុយបួននាក់អញ្ចឹងទៅកាំបិទឆ្កកអញ្ចឹងទៅ  ទៅដល់នឹងគេយកបណ្តើរទៅ  អង្គុយទៅ  ស្លាបសេកចងស្លាបសេកជាប់អញ្ចឹងអង្គុយនៅមាត់រណ្តៅទៅភីសភូស  ភីសភូសវាយ(សំលាប់)ទៅណាស់។

ក៖  ចា៎។

ខ៖ អាខ្លះទៅវា វាស្រវឹងវាដល់កំណត់ទៅហាំ ជំនាន់វាយ(សំលាប់)បងចិតប្រាំ(១៩៧៥)នឹងហាំ ពួកវានឹងពួកយោធានឹងផឹកសុទ្ធតែស្រា អាខ្លះដល់វាស្រវឹងមែនទែនទៅវាយមនុស្សអត់ងាប់ទេវាយគរ លើគ្នាហាំ។

ក៖ ចាំ។

ខ៖ វាយគរៗដូចថាអាយុវាមិនទាន់អស់អញ្ចឹងទៅណាស់ឈ្មោះពូសួរៗអ្នក អ្នកចិតប្រាំនឹងយកទៅវាយចោលជាមួយបងនឹងប្រពន្ធគាត់អូ....អត់ទាន់មានប្រពន្ធទេទៅវាយ វាយទៅគាត់វាដល់ម៉ោងវាវាយអស់ហើយគាត់មានទាន់ងាប់អី ណាគាត់ធ្វើជាងាប់ហាំណា។

ក៖ ចាំ។

ខ៖ ទៅគាត់ខំស្រវ៉េស្រវ៉ាៗកាយលូនចេញមកចេញតែយប់ទេថ្ងៃនឹងពួនហើយគាត់រស់នឹងទឹកសន្សើមទេគាត់ក៏រស់នៅទៅដល់អាមេរិក គាត់មកធ្វើបុណ្យប្រវត្តិគាត់អាពតវាយៗធាក់ទម្លាក់ក្នុងរណ្តៅគរលើគ្នាហើយនឹងហាំ។

ក៖ ចាំ។

ខ៖ រួចបើកូនក្មេងវិញក្មួយអើយចាក់មេក្រូទ្របហឹងលឺសូតែភូសៗវាចាប់ជើងបោកហាំចាប់ជើងបោកនឹងដើមចំការក្រូច ចំការមៀនអីទីនឹងវាធ្វើមន្ទីយោធានឹងសម្រាប់ចាប់មនុស្សដាក់គុកវាយធ្វើបាបអីនៅកន្លែងនឹងគេហៅថា មន្ទីយោធា។

ក៖ ចាំ។

ខ៖ អឺម....មន្ទីយោធានឹងសម្រាប់ចាប់យកទៅធ្វើបាបនៅទីនោះ ដល់មកជំនាន់វាយអ្នកចិតប្រាំនឹងដឹករទេះគោទៅអញ្ចឹង ក្មេងតូចៗអញ្ចឹងអើវាមានទៅដឹងអីម្តាយបញ្ចុកបាយអញ្ចឹងទៅដល់ម៉ោងគេ ដល់ម៉ោងគេវាយអស់ហើយគេ បណ្តើរទៅទៀតបញ្ចុកបាយកូនក្មេងតូចៗនឹងអញ្ចែកអាណាតូចចាប់បោះអញ្ចឹងទៅជំពុះទង់ទ្រពីក្រោមអញ្ចឹងទៅណា។

ក៖ កាំភ្លើង?

ខ៖ អឺម....ទៅដល់តែរាងទ្រើសតិចៗចាប់បោក ចាប់បោកនឹងដើមក្រូចដើមមានអស់ហើយសំបកនៅតែខ្លឹមទេក្មួយ។

ក៖ អំរ...។

ខ៖ ទៅមើលឥឡូវកន្លែងនឹងគេកាប់ធ្វើចំការ។

ក៖ កូនក្មេងគេសំលាប់ដែរណ៎?

ខ៖ ថាទៅឃើញតែចានបាយម្ដាយកំពុងតែបញ្ចុកបាយនឹងហា៎ដល់ម៉ោងគេយកទៅវាយចោលក្មេងគេអត់យកទៅវាយចោលជាមួយម្ដាយទេ តូចៗនឹងហា៎គេចាប់បោក។

ក៖ ចាប់បោកនឹងដើមឈើ។

ខ៖ ចាប់បោកនឹងដើមឈើយួរជើងទៅលើលីស្រែកមេក្រូបែរមកលីវាដាក់មេក្រូទៀតហា៎។

ក៖ ដាក់មេក្រូអោយយើងស្ដាប់ទៀត?

ខ៖ អឹម...ថាសាហាវណាស់ណាក្មួយមួយជំនាន់ម៉ែអាហ្នឹងអ្នកចិតប្រាំ ដែលចិតប៉ុន្មានមើលនៅក្នុងអាពតដែរនឹងគេហៅសៃមួយៗនឹងគេវាយអ្នកប្រវត្តិ ប្រវត្តិពីសង្គមធ្វើការ ដូចប៉ូលីស ធ្វើសៃប ធ្វើគ្រូ ធ្វើស្អីៗនឹង នឹងគេដាក់ ឡានឃ្លុបដូចឡានទាហ៊ានសព្វថ្ងៃដឹកគ្រាប់ដឹកទាហ៊ានអញ្ចឹងហា៎៕

ក៖ ចា៎។

ខ៖ ឡានអញ្ចឹងដាក់ពេញអញ្ចឹងទៅដល់អណ្ដូងបារាំងគេហៅអណ្ដូងចំការកៅស៊ូនឹងបារាំងមានតែមួយរយម៉ែត្រណាស់។

ក៖ ចា៎។

ខ៖ បានមានទឹក ដីក្រហមហា៎។

ក៖ ចា៎។

ខ៖ រួចទៅគេធ្វើមាត់អណ្ដូងនឹងវាតែបួនជ្រុងធ្វើបួនជ្រុងពីម៉ែត្របួនជ្រុងអញ្ចឹងហា៎យើងបោះអីទៅលីតែរើង....ដូចយើងទម្លាក់អីចន្រ្ទៃនៅលើភ្នំសន្ទុកអញ្ចឹងលីតែរើង...អញ្ចឹង។

ក៖ ព្រោះវាជ្រៅ។

ខ៖ អើត្រូវណាស់មើលឃើញងងឹតឈឹងត្រូវនៅក្នុងចំការកៅស៊ូទៀត គេធ្វើនៅក្នុងចំការនឹង ដល់ទៅពេញឡានអញ្ចឹងគេធ្វើអាដងថ្មឹងប៉ប៉ុនម៉ាត់អណ្ដូងនឹងទៅណាស់។

កៈ ចាំ។

ខៈ គេធ្វើអា.... អាឈើទាញទម្លាក់ទៅហ៎ណាស់។

កៈ ចាំ។

ខៈ ទាញទម្លាក់អញ្ចែកដុំថ្មនឹងទៅទយឡាក់រៀបបាញ់រៀបនឹងយកទៅចាក់នឹងអត់មានសំលាប់នឹងគ្រឿងអាវុធអីទេគេបាញ់ថ្នាំបំពុលនៅក្នុងឡានសិន។

កៈ អ៎រ.....?

ខៈ ម៉ែច្រើងនឹងហាំមួយគ្រួសារគាត់នឹងហាំនៅរស់ប៉ុន្មាននាក់ កូនប៉ុន្មានពីដណ្ដប់នាក់(១២នាក់)ហាំ នៅសល់តែប៉ុន្មាននាក់បួននាក់ទេណាស់ នឹងមួយជំនាន់គាត់នឹងឪពុកគាត់ធ្វើសែបហាំ។

កៈ ចាំ។

ខៈ ធ្វើសែបប៉ូលីសអញ្ចឹងរួចគាត់កំពូលអ្នកមានគេហៅសក្ដិភូមិ នឹងគេហៅសក្ដិភូមិជំនាន់អាពតហាំដល់អញ្ចឹងបាញ់ថ្នាំបំពុលអញ្ចឹងទៅបានទយឡាននឹងចាក់។

កៈ ចាក់ទឹងរស់។

ខៈ ចាក់ទាំងរស់នឹងណាស់ចាក់ពីរបីឡានអញ្ចឹងទៅបានទាញអាដងត្លឹងទម្លាក់អោយទ្រមទៅទយចាក់ទៀតទៅក្មួយ វេទនាណាស់សៃមួយនេះចាក់ចូលក្នុងអណ្ដូងម៉ងណាក្មួយរួចទៅទាញ ទាញដងថ្លឹងទម្លាក់សង្កត់បុកទម្លាក់ៗថ្ម។

កៈ ហើយអញ្ចឹងមិនអាចរស់ទេ..ជ្រៅណាស់។

ខៈ ហ៊ឺ..រស់អីក្មួយរស់ស្អីបើវាទយចាក់អណ្ដូងមួយរយម៉ែត្រទៅហើយ អណ្ដូងហាំទយចាក់ៗមួយឡានទៅបុកចាក់មួយឡានទៅលើកទម្លាក់ថ្មបុកទែងដងថ្លឹងទែងទម្លាក់ៗទ្រោមចាក់ទៀតទ្រោមចាក់ទៀតណាក្មួយ។

កៈ ចាំ។

ខៈ អឺម....នឹងអញ្ចឹងជំនាន់នឹងវេទនាណាស់បានថារស់ពីអាណាគ្គិនឹងមក កាលមួយជំនាន់លន់ណុលយើងវេទនានឹងកប៉ាលហោះទម្លាក់គ្រាប់បែក ដល់ម៉ោងបីឡើងម៉ោងពីរឡើង

អ្នកកូនច្រើនដាំបាយឆ្អិនហើយអោយស៊ីអោយរួច ហើយកាប់រណ្តៅសុខគេហៅរណ្តៅប្លង់សេអញ្ចឹងណាស់ ជីកទៅក្រោមអញ្ចឹងទៅ ទៅធ្វើសសរ ធ្វើអីគងទៅយកអីក្រាលទៅចាក់ដីលុបទៅរណ្តៅប៉ប៉ុននឹងទៅនៅក្រោមដើមឈើហើយដើមឈើធំមួយអញ្ចឹងទៅរណ្តៅអញ្ចឹងមើលតែលឺស្នូរងឿង..ហើយនឹងងឿងមកទម្លាក់បាញ់តែម្តងក្មួយតែម៉ោងប្អូនដឹងតែមកហើយបើមិនអញ្ចឹងទេយប់កំពុងដេកនឹងតែលឺងឿងពន្លត់ចង្កៀងអស់ហើយ នឹងជំនាន់លន់ណុលហា៎៕

ក៖ ចា៎។

ខ៖ មកឆ្លងកាត់ ឆ្លងកាត់នៃកអា...កប៉ាលហោះទម្លាក់គ្រាប់បែកនឹងហើយមកអាពតនឹងទៀតខ្លាំងជាងលន់ណុលទៀត មួយជំនាន់លុនណល់ទម្លាក់គ្រាប់បែកស្រុកបាតុកម្មកើតសង្គ្រាមនឹង រួចពីគ្រាប់បែកហើយមក មកកាំបិត ពូថៅ៕

ក៖ ចុះអ្នកមីងកាលអ្នកមីងរៀបការឪពុកម្តាយជាអ្នករៀបចំអញ្ចឹងហ៎?

ខ៖ នឹងហើយម្តាយមីងរៀបចំតើគេស្តួរម៉ែឪនឹងទៅណាស់រៀប។

ក៖ ខាង ខាងប្រុសគាត់ចូលស្តួរតាមប្រពៃណី?

ខ៖ នឹងហើយៗ ចូលស្តួរតាមប្រពៃណីយើងប៉ុនគ្មានអីទេក្មួយមានបាយណា ទៅហូបបាយរួម។

ក៖ ចា៎។

ខ៖ គេមិនអោយមានឆ្នាំងមិនអោយមានចាននៅផ្ទះទេគេប្រមូលយកទៅដាក់រួមអស់ហើយ។

ក៖ ពីជំនាន់នឹងមានថ្លៃបណ្តាការមានថ្លៃអីអត់អ្នកមីង?

ខ៖ យកទៅចាយអីណាក្មួយបើមាស មាសនៃកពួកវាពួកអាពតវាយកវាយមនុស្សទៅ វាយកខ្សែតឹងតម្លឹងៗយកមកអូសពាក់អោយឆ្កែនឹងយកទៅចាយជាមួយពីណាបើស៊ីបាយរួមហ៎។

ក៖ អរ...អញ្ចឹង។

ខ៖ មានស្រូវមានអង្ករមានចានមានឆ្នាំងអីណានៅតាមផ្ទះមានតែកម្សៀវកញ្ចាស់មួយគ្រាន់ស្មោរជំឡូងនឹងតែត្លើងហុយងាប់ទៀតនឹង។

ក៖ គេធ្វើម៉េចខ្លះទៅអញ្ចឹងបើរៀបការអត់មាន?

ខ៖ តែដូចមីងនិយាយអញ្ចឹងមានធ្វើអីអោយយើងទៅប្តេជ្ញាចិត្តក្នុងមួយហិចតាអោយបានបីតោនទៅប្រាំតោន។

ក៖ អរ...។

ខ៖ យកកំលាំងបញ្ចេញកំលាំងនឹងអោយអស់ពីសម្តភាពដើម្បីជូនជាតិ។

ក៖ អ..ចាំ។

ខ៖ នឹងហើយ។

ក៖ អញ្ចឹងមានន័យថាអើ....ប្តីអ្នកមីងគាត់អត់ដែលបានជួបគ្នាពីដំបូងមកទេ?

ខ៖ អត់ទេនៅក្នុង..។

ក៖ ស្គាល់គ្នា?

ខ៖ នឹងហើយចាស់ៗនឹងអ្នក គាត់អ្នកនៅស្រុកភូមិស្វាយទាបនឹងអញ្ចឹងគាត់នៅថ្នល់លេខប្រាំបួនមីងនៅថ្នល់លេខប្រាំមួយនេះ។

ក៖ នៅភូមិស្រុកជាមួយគ្នា។

ខ៖ នឹងហើយ នឹងហើយប៉ុន្តែគេស្រុកកំណើតម៉ែឪគេខាងទន្លេហានជ័យនោះទេ។

ក៖ ចាំ។

ខ៖ ប៉ុន្តែទៅដល់គាត់នេះទៅគាត់មកនៅថាដីស្រុកចំការលើស្រួលដាំជំនាំធ្វើចំការធ្វើអីនៅស្រុកទន្លេដីវាចង្អៀតអញ្ចឹងហំណាស់៕

ក៖ ចាំ។

ខ៖ គេរកស៊ីមានបានតិចតួច គេខ្ជិលនៅស្រុកកំណើតគេមកចេញមកនៅរកស៊ីអញ្ចឹងទៅ។

កៈ ចុះអ្នកមីងអើ....អ្នកមីងចេះអាននឹងចេះសរសេរភាសាខ្មែរអត់?

ខៈ អឹម...មិនលឺមីងនិយាយទេ ? មីងបានថ្នាក់ទីពីរទេបានប៉ុន្មានខែវាទម្លាក់សម្តេចនឹងកើតមានអញ្ចឹងទៅ ដល់គ្រប់អាយុចូលនឹមអាពតទៀតនឹងមានបានរៀនសូត្រស្អី៕

កៈ មីង..កាលអ្នកមីងមុនអាពតអ្នកមីងចូលរៀនអញ្ចឹង?

ខៈ បានរៀនគ្រប់ក៏មិនបានរៀនប៉ុន្មានដែរក្មួយអើយអាល័យទៅឃ្វាលគោឃ្វាលអីគ្មានបានរៀនអីអាយើងដាច់អាពត.....នឹងហើយ។

កៈ អញ្ចឹងអ្នកមីងរៀនបានថ្នាក់ទីពីរ?

ខៈ ថ្នាក់ទីពីររៀនបានបីខែនឹង។

កៈ ចាំ។

ខៈ អឹម.....។

កៈ ហើយសាលារៀនអ្នកមីងនៅឯណាដែរ?

ខៈ នៅស្វាយទាបនឹង។

កៈ សាលាស្វាយទាប?

ខៈ សាលាស្វាយទាបតែម្តង។

កៈ បបមសិក្សាស្វាយទាប?

ខៈ នឹងហើយអាសាលានឹងកេរ្តិ៍ដំណែលសាលាពីដើមនឹងមក រុសបាត់ហើយសាលាមីងហាំគេរុសយកទៅធ្វើរោងបាយ។

កៈ ចាំ។

ខៈ ធ្វើកន្លែងរោងបាយអស់ហើយផ្ទះណាធំៗយកទៅធ្វើជង្រុកស្រូវធ្វើរោងបាយអស់ហើយវាបំផ្លាញណាស់អាពតហាំ ពួកអ្នកនៅតាមជួរថ្នល់នឹងហាំសុទ្ធតែផ្ទះសក្តិភូមិពួកនាយទុនយកវាយចោលអស់ហើយរស់តែតាទេ៕

កៈ ចាំអ្នកមីង។

ខ៖ រស់តែតាទេក្រៅពីនឹងយកវាយចោលខ្មោចហើយ បើមិនអញ្ចឹងទេផ្ទះនឹងយកជូនរដ្ឋជូនអង្គការអញ្ចឹងទៅអង្គការយកទៅធ្វើរោងបាយទៅ ធ្វើជង្រុកស្រូវអស់ទៅ ទៅអារធ្វើកន្ទេតកន្ទាត់ខ្មោចខ្ទីអស់ហើយវាបំផ្លាញអស់ហើយវា..។.

ក៖ អ្នកមីងមានអើ..មិត្តភក្តិជិតស្និទ្ធដែលធំធាត់ជាមួយគ្នាអត់ កាលពីក្មេង?

ខ៖ ហៃក៏មិនមាន(ម៉េចក៏មិនមាន)។

ក៖ ពួកគាត់មានឈ្មោះអីដែរអ្នកមីង មិត្តភក្តិជិតស្និទ្ធ?

ខ៖ អ្វូយ...គេទៅមានប្តីមានអីទៅឆ្ងាយៗអស់ទៅហើយ។

ក៖ អត់បាននៅរាប់អានគ្នាទាល់ឥឡូវ។

ខ៖ អត់បាន អត់បាននៅជិតទេអត់ទេដល់ពេលខែបុណ្យទានអញ្ចឹងទៅម៉ែឪគេនៅនឹងទៅគេមកទៅគេមកលេងអីមក។

ក៖ ចាំ។

ខ៖ នឹងអញ្ចឹង។

ក៖ ចុះអ្នកមីងធ្វើកិច្ច...ធ្វើការងារអីដែរ?

ខ៖ អើយ...មីងបានធ្វើអីក្មួយអើយលីមីងថាមួយខែចិញ្ចឹមដល់ខែពេទ្យ ដល់ខែពេទ្យមីងធ្វើអីកើតតាំងពីឈឺ ចេញអាសញ្ញារោគទឹកនោមផ្អែមនឹងមក មីងទន់ទេស្វម្បីតែជិះកង់ក៏មីងជិះមិនកើតដែរក្មួយមីងនៅទន់នឹងឯង ទន់ៗនឹង៕

ក៖ អញ្ចឹងតាំងពីដើមមកអ្នកមីងពេលរៀបការហើយចេញពីអាពតមកអឺ..អ្នកមីងអត់បានធ្វើអីទេន៎?

ខ៖ ធ្វើចំការ។

ក៖ ធ្វើចំការចុះប្តីអ្នកមីងគាត់ធ្វើចំការដែរ?

ខ៖ ធ្វើចំការទាំងអស់គ្នានឹងដល់មកពេញប៉ែតប្រាំមួយនឹងក៏បែកគ្នាកូនបួននឹងទៅ។

ក៖ ចាំ។

ខ៖ បែកគ្នា។

ក៖ អញ្ចឹងគាត់នៅរស់ទេ?

ខ៖ ស្លាប់បាត់ហើយ។

ក៖ អូ៎រ......គាត់ស្លាប់ដោយសារអីអ្នកមីង?

ខ៖ ស្លាប់ ស្លាប់កូនទីបួននឹងមីពៅនឹងបីទទឹងអញ្ចេកមិនទាន់បើកភ្នែកឃើញមុខឪពុកម៉េចផងនឹងកើតមកហ៎...។

ក៖ គាត់ឈឺឬក៏យ៉ាងម៉េចអ្នកមីង?

ខ៖ ទៅជីកមាសតែចាញ់។

ក៖ អូ៎រ..ចាញ់។

ខ៖ ចាញ់។

ក៖ ចាញ់ តើអ្នកមីងបានធ្វើការអ្វីខ្លះទៀតទេនៅក្នុងជិវិត?

ខ៖ ក្នុងជិវិតនឹងកាលកូននៅតូចៗនឹងទិញស្រូវគេតិចតួចមក ទៅកិនលក់ទៅកិនធ្វើជាអង្ករទៅលក់ទៅ ទៅវាជំងឺដុនដាបតាំងពីជំនាន់កូននឹងកើតមកបានប្រាំបីដណ្តប់ថ្ងៃ(១៨ថ្ងៃ) នឹងយើងធ្វើការធ្ងន់នឹងក៏ជំងឺនឹងពីមុនដល់កុំតែមានម៉ែឪនៅមើលខុសត្រូវក៏មីងស្លាប់មិនឃើញមុខកូនទេទីបួននឹងហ៎..ព្រោះកូននៅតូចៗនឹង បីពី បីពីកូនបួន៕

ក៖ អញ្ចឹងអ្នកមីងចិញ្ចឹមកូនតែម្នាក់ឯង?

ខ៖ ម្នាក់ឯងបានឪពុកដ៏ឈឺទៅឈឺខ្វិនណាក្មួយ។

ក៖ ចា៎។

ខ៖ តែទាស់ត្រឹមមីកូនទីបួននឹងមីឆ្នាំខាលនឹងណា មីឆ្នាំប៉ែតប្រាំមួយ(១៩៨៦)កើតនឹងណាមីឆ្នាំប៉ែតប្រាំមួយហា៎..។

ក៖ ចា៎។

ខ៖ មីងទាស់ ទាស់ខ្វិនណាស់។

ក៖  ចាំ។

ខ៖  ទាស់ឡើងខ្វិនហាំ  ត្រង់នឹងដែលដុនដាបជំងឺតាំងពីនឹងមករួចតែពីទាស់នឹងទៅ  ទៅជាកើតអាទឹកនោមផ្អែមនឹងដល់កូនដឹងវ័យពេញវ័យ  ពេញវ័យមកកូនក៍រៀនបានតិចតួចនឹងស្តាយកូនហាំ។

ក៖  កូនអ្នកមីងគាត់អើ...ឈ្មោះអីខ្លះដែរអ្នកមីង?

ខ៖  ឈ្មោះភន  លៀងអ៊ឹម  ភន  លៀងអេង  ភន  ឆេងអាន  ភន  លៀងអ៊ី  ប្រុសពីរ ស្រីពីរ។

ក៖  ចាំ  ហើយឥឡូវនឹងពួកគាត់ធ្វើការងារអ្វីខ្លះ?

ខ៖  អើយ...រត់ម៉ូតូឌុបនៅភ្នំពេញក្មួយអើយផ្ទះជួលគេទេគ្នាសុទ្ធទៅនៅមិនទាន់បានស្រួលនៅឡើយទេកូនរៀនផងបានអង្គការ..បើឈ្មោះភន  លៀងអេងនឹងបានកូនស្រីមួយបងគេនឹងចូលរៀនភាសាអង់គ្លេសក្រុមអង្គការអាមេរិកទៅណាស់៕

ក៖  ចាំ។

ខ៖  បានគេជួយតាំងពីបានចូលរៀនសាលានឹងមកគេឧបត្ថម្ភអោយអញ្ចឹងទៅបានសំលៀកបំពាក់អីមិនដែលអស់លុយយើងមួយរៀលទេដែលស្លៀកទៅនៅសាលានឹង៕

ក៖  ចាំ។

ខ៖  ដែលគេជួយកង់ជួយអីនឹងទៅអង្ករអីនឹងគេអោយប្រាក់ស៊ីវាល់ខែនឹងម៉ែឪវាបានអង្ករល្បបកូននឹងហាំ។

ក៖  អញ្ចឹងកូនអ្នកមីងគាត់រៀបការហើយប៉ុន្មាននាក់ហើយ?

ខ៖  បានរៀប....បានពីរ...ពីរនៅសល់ពីរទៀតទីបីទីបួន។

ក៖  ទីបីទីបួន?

ខ៖  ប្រុសមួយ  ប្រុសពីរ  ស្រីពីរ។

ក៖  រៀបការហើយពីរនាក់  នៅពីរនាក់។

ខ៖ នៅពីរ។

ក៖ ចាំ។

ខ៖ នឹងហើយ។

ក៖ ហើយកូនអ្នកមីងគាត់ធ្វើការនៅណាដែរ?នៅ....?

ខ៖ អើ....ធ្វើការរោងចក្រនឹងនៃកក្មួយ។

ក៖ នៅអត់...គាត់នៅក្នុងខេត្តកំពង់ចាមនឹងដែរអត់?

ខ៖ នៅភ្នំពេញហាំក្មួយ។

ក៖ នៅភ្នំពេញទាំងអស់គ្នា។

ខ៖ នឹងហើយទៅក៏រៀនបានមីពៅគេរៀនបានតែថ្នាក់ទីបីទេក្មួយអើយបើបី បីទៀតរៀនបានថ្នាក់ទីបួនស្តាយណាស់មកបច្ចុប្បន្ននេះគេកំពុងតែជឿនលឿនរើសសុទ្ធអ្នកចេះភាសាតែកាលនឹងមីងកំពុងវេទនាឪពុក ឪពុកចាស់បានមានឪពុកទេកុំអីនឹងមីងមិនបានឃើញមុខកូនទេយើងឈឺ ណាមើលមីងផងណាចិញ្ចឹមចៅផងណាស់។

ក៖ ចាំ។

ខ៖ ណាចៅរៀនដល់ទៅរៀននៅស្ទឹបបឋម វិទ្យាល័យ វិទ្យាល័យវានៅថ្នល់បែកអត់មានកង់អត់មានអីជិះឈប់រៀនទៅណាក្មួយ។

ក៖ ចាំ។

ខ៖ ស្តាយកូនណាស់កូនរៀនពូកែណាស់...។

ក៖ ចាំ។

ខ៖ ប៉ុនទៅយើងវាខ្វះខាត រួចវាដើរតិចគីឡូដីណាស់ក្មួយឯងគិតមើល។

ក៖ ចាំ អ្នកមីង។

ខ៖ សាលាវីទ្យាល័យនៅថ្នល់បែកហើយពីស្វាយទាបទៅក្មួយឯងគិតមើលតិចគីឡូណាស់។

ក៖ ចាំ។

ខ៖ អញ្ចឹងបានទៅវេទនាទៅក៏ឈប់រៀនទៅធ្វើការរោងចក្រទៅនឹងអញ្ចឹងស្តាយកូនបើនៅលំបាកដូចឥឡូវនឹងទៅធំៗ កាលនឹងកូននៅតូចៗវាកំពុងពេញរៀនមានចេញទៅធ្វើការអីកើតដល់វាទ្រើសទៅវាឈប់រៀនវាឈប់អីទៅវាខ្វះខាតមុខក្រោយអញ្ចឹងទៅក៏កូនទៅធ្វើការរោងចក្រនឹងទៅស្រណោះកូនមួយឆាកជិវិតនេះស្រណោះកូន បង្កើតកូនមកគ្មានអីសម្រាប់កូន កូនដឹងក្តីឡើងកូនទីពឹងម្តាយ ម្តាយជរាបានម៉ាត្រឹមមើលឃើញថា កូនដល់អនាគតកូនស្តាយផ្ទុងផ្តើមការរៀនសូត្ររបស់កូនបើបានរៀនចេះដឹងដល់ថ្នាក់ទីប្រាំបួនទីប្រាំពិលនឹងគេវិញមីងអត់សូវសោកស្តាយទេកូនបាន វាតូចជាងគេវាកើតឆ្នាំប៉ែតប្រាំមួយបានតែថ្នាក់ទីបីទេ៕

ក៖ ចាំ។

ខ៖ បានតែថ្នាក់ទីបីទេកូនទៅស៊ីឈ្នួលគេណាស់ទៅស៊ីឈ្នួលគេរហូតអីឡែមងណោះក្មួយទៅជួយលក់ឥវ៉ាន់គេហាំមីពៅនឹងហាំ។

ក៖ ចាំ។

ខ៖ អភ័ព្វអាណិតកូនដឹងក្តីឡើងកូនបែកពីខ្លួនទល់នឹងសព្វថ្ងៃ ទល់នឹងសព្វថ្ងៃមីតូចនឹងអាណិតជាងគេតូចជាងគេកំសត់ជាងគេកើតមកបែកឪតាំងពីអាយុបីបី..បីដណ្តប់ថ្ងៃ(១៣ថ្ងៃ)ហាំក្មួយបីដណ្តប់ប្រាំបីដណ្តប់ថ្ងៃ(១៨ថ្ងៃ)ណាក្មួយ។

ក៖ ចាំ។

ខ៖ មិនទាន់ចេះមិនទាន់មើលឃើញអីទេណាស់មិនទាន់ស្គាល់ទេណាស់។

ក៖ អញ្ចឹងចុះអ្នកមីងតាំងវ័យក្មេងមករហូតដល់ឥឡូវនឹងជិវិតអ្នកមីងមានការផ្លាស់ប្តូរអ្វីខ្លះនិយាយពីជំនាន់មុននឹងជំនាន់នេះ?

ខ៖ អើយជំនាន់មុននឹងវាលឺបដូចក្បាលដែកគោលឥឡូវបានកូនដូចថាអាអ្នកក្រៅបន្ទុកវារៀបបានពីនឹងគ្នាក៏មិនទាន់ធូរធារមិនទាន់មានផ្ទះមានសម្បែងអីដែរក្មួយអើយដូចមីងនិយាយអញ្ចឹងអោយបានអោយតែវាបានរស់ស្រួលប្តីប្រពន្ធសុខសាន្តកូនចៅក្រុមគ្រួសារវាទៅចុះ មីងបានអាក្នុងបន្ទុកបានអាក្នុងបន្ទុកនឹងក៏វាមិនទាន់បានធូរធារអីប៉ុន្មានបើបានអីនឹងសល់ក្មួយអើយកូនចង់សប្បាយចង់អីមើលបើមានលុយមិននៅមួយបង្វិចប៉ប៉ុណ្ណឹងទេ មីងដេកអោយតែមានដំបូលជ្រកទេមីង មើលចុះរកតែផ្លូវដើរគ្មានរាល់ថ្ងៃនេះ៕

កៈ  អញ្ចឹងជិវិតពីមុននឹងឥឡូវខុសគ្នាម៉េចដែរអ្នកមីង?

ខៈ  គ្រាន់តែប្រែប្រួលម៉ាតិចកូនវាបានវាទ្រើសវាបានធ្វើការអីចេះរកអីខ្លួនវាអាមានគ្រួសារនឹងទៅ     វានៅតែអាក្នុងបន្ទុកនឹងទៅវាមិនទាន់មានអីដែលសម្រាប់ទុកដាក់នៅឡើយបានមួយខែអស់មួយខែមួយខែអស់មួយរ៉ាស់ៗទេក្មួយអើយ   អោយថាសល់អោយមានគ្មានអីមានទេក្មួយឯងមើលបើមានមិនមែននៅក្នុងដីមួយប្រលោះអត់មានផ្លូវដើរអញ្ចឹងទេ   ត្រូវដើរចេញប៉ុន្តែមិនដឹងធ្វើម៉េចយើងវាអត់ចេះតែនៅៗទៅងាប់ទៅរកផ្លូវសែងចេញមិនឃើញទេ៕

កៈ  អញ្ចឹងអ្នកមីងនិយាយពីម្ហូបវិញតើអ្នកមីងចូលចិត្តហូបម្ហូបអ្វីដែរពីក្មេងមកដល់ឥឡូវ?

ខៈ  អើយ...មីង   មីងមិនសូវជាអ្នករើសអីទេក្មួយអើយមិនសូវជារើសស្អីក៏ហូបកើតដែរអោយតែមាន។

កៈ  ល្បែងអីខ្លះដែលអ្នកមីងចូលចិត្តលេង?

ខៈ  អើ..ល្បែងលេងនៅពេលចូលឆ្នាំអីទៅបើឆ្នាំនេះចប់។

កៈ  តាំងពីក្មេងដល់ឥឡូវល្បែងក្មេងៗលេងអីណាស់?

ខៈ  អ៊ូស...ល្បែងមីងចូលចិត្តសប្បាយដើរមើលគេរាំគេរែកនឹងចូលចិត្តហាំ។

កៈ  ចាំ។

ខៈ  ចូលចិត្តអាគេរាំអ្នកចម្រៀងអីច្រៀងអីអញ្ចឹងចូលចិត្តហាំ។

កៈ  ចាំ   អញ្ចឹងអ្នកមីងបានចងចាំចម្រៀងណាដែរខ្លះដែលអ្នកមីងបានតាំងពីក្មេងមកដល់ពេលនេះហាំអ្នកមីងចូលចិត្តចម្រៀងម៉េច?

ខៈ  មីងចូលចិត្តតែចម្រៀងសាមុតទេ។

កៈ  បែបសាមុតណំ.....?

ខៈ  បទសាមុតស៊ីន   ស៊ីសាមុតពីពីសង្គមអីណាស់។

កៈ  ចាំ។

ខ៖ គេចាក់ម្តងៗអាមានឌីសកា........ស្អីគេលក់នោះគេចាក់ឌីសប៉ុន្មានពីពាន់ប៉ុន្មានបទនឹងគេចាក់ពិរោះហ៊ីណាស់ពីដើមរោងកុននៅថ្នល់លេខប្រាំពិលទីនេះនឹង។

ក៖ ចាំ។

ខ៖ អឺ....ឆ្លងថ្នល់ទៅរោងកុននៅជិតផ្ទះអ៊ុំធំនឹងបងឪពុកនឹង។

ក៖ រហូតដល់ឥឡូវអ្នកមីងចូលចិត្តតែបទស៊ិន ស៊ីសាមុត។

ខ៖ នឹងហើយចូលចិត្តណាស់។

ក៖ ចុះតើអ្នកនៅក្នុងគ្រួសារអ្នកមីងមានអ្នកណាគេចេះលេងឧបករណ៍ភ្លេងអីទេ?

ខ៖ គ្មានទេក្មួយអើយអត់មានទេ។

ក៖ ចុះ ចុះផ្ទះរបស់អ្នកមីងមានលក្ខណះម៉េចដែរតាំងពីក្មេងរហូតដល់ឥឡូវនេះប្រែប្រួលអីម៉េចពីមុនផ្ទះរបៀបម៉េចឥឡូវផ្ទះរបៀបម៉េច?

ខ៖ កាលពីមុនដែលកូននៅតូចៗផ្ទះមីងភ្លៀងមកទឹកលិចប្ងូនកាំ។

ក៖ ចាំ។

ខ៖ ប្ងូនកាំពីលើក៏លិចលិចស្រក់ពីលើលិចពីក្រោមក៏លិចវេទនាណាស់ក្មួយមកបានប៉ប៉ុននេះហើយដីមួយច្រកប៉ប៉ុនតែមួយផ្ទះរកតែផ្លូវដើរគ្មានដើរដីគេធ្វើម៉េចបើមានលុយ មីងមើលទៅក្មួយឯងមកដើរឃើញហើយគ្មានផ្លូវដើរទេ។

ក៖ ផ្ទះអ្នកមីងពីមុនធ្វើពីអីដែរ?

ខ៖ ពីឈើប្រក់ស័ង្កសី។

ក៖ ចុះឥឡូវ?

ខ៖ ឥឡូវបានស័ង្កសីដែរបានជញ្ជាំងថ្ម។

ក៖ ចាំ កូនធ្វើអោយអ្នកមីង។

ខ៖ កូនធ្វើអោយនឹងហាំក្មួយអើយនៅជំពាក់លុយរដ្ឋទល់សព្វថ្ងៃណា ណាលៃទិញថ្នាំអោយម្តាយចិញ្ចឹមម៉ែផងថ្នាំមួយខែៗប្រាក់ខែគ្នាបានប៉ុន្មានគ្នាសុខចិត្តអត់ណាបង់រដ្ឋ។

ក៖ ចាំ ផ្ទះអ្នកមីងប៉ុន្មានគុណប៉ុន្មាន?

ខ៖ អាអញ្ចែកប្រាំមួយ អាអញ្ចែកប្រាំបួនក្មួយជំរៅ។

ក៖ បណ្តោយប្រាំបួនទទឹងប្រាំមួយ។

ខ៖ បណ្តោយប្រាំបួនទទឹងប្រាំមួយនឹងហើយ។

ក៖ ហើយអត់មានផ្លូវទេ។

ខ៖ អត់មានផ្លូវទេ។

ក៖ ចាំ។

ខ៖ អត់មានផ្លូវដើរទេគេជិតខាងនឹងគេយកដីជាផ្លូវនឹងគេអូសទាញជាកម្មសិទ្ធិរបស់គេទៅមិនហ៊ានមាត់ទេខ្ជិលសូមតែសុខទៅចុះ។

ក៖ ចុះអ្នកមីងអើ.....អ្នកមីងប្រាប់ពីភាពលំបាកនៅក្នុងជិវិតរបស់អ្នកមីងបានអត់?ថាអ្នកមីងលំបាកអ្វីខ្លះហើយឆ្លងកាត់លំបាកអីខ្លះកន្លងមក?

ខ៖ អើយ...មីងវាលំបាកនឹងតាំងពីដឹងក្តីមកទល់នឹងមានកូនបួននឹងតាំងពីចាប់ពីអត់ពីប្តីទៅទល់នឹងកូនទ្រើសៗនឹងមីងមិនទាន់បានធូរនៅឡើយទេក្មួយអើយ។

ក៖ ពិបាករហូតនឹង។

ខ៖ នៅតែកូនចៅនឹងវាមិនទាន់មានទីជម្រកជ្រក ក្រោកមកធ្វើការរត់ម៉ូតូអញ្ចឹងវាជួលផ្ទះគេ។

ក៖ ចាំ។

ខ៖ រួចជិវិតរត់ម៉ូតូក្មួយឯងគិតមើលជូនផ្គរជូនភ្លៀងជូនបានជូនអត់ណាស់៕

ក៖ ចាំអ្នកមីង។

ខ៖ ជួនកាលទៅអត់បានសោះក៏មានដែរណាក្មួយ។

ក៖ ចាំ។

ខ៖   រួចទៅថ្លៃផ្ទះគេរួចកូនរៀនទៀតក្មួយឯងគិតមើល      នឹងបានអាកូនធំកូនស្រីនឹងបានអង្គការខាងអាមេរិកទេណាស់គេជួយចិញ្ចឹមជាអង្គរសំលៀកបំពាក់មួយនឹងអត់មានអស់ពីម្ដាយឪពុកទេណាស់   ចុះនៅពីបីទៀតតូចៗដែលមិនទាន់រៀនមិនទាន់ចេះហូបបាយខ្លួនឯងនោះ។

ក៖   ចុះអ្នកមីងមានចៅប៉ុន្មាននាក់ហើយ?

ខ៖   ចៅប្រាំពិល(៧)ហើយ។

ក៖   ចៅប្រាំពិលនាក់?

ខ៖   ហ្នឹងហើយ។

ក៖   កូនបងគាត់អើយកូនអឺ..ប៉ុន្មានដែរ?

ខ៖   កូនបងតែពីរទេ?

ក៖   កូនទីពីរ?

ខ៖   កូនទីពីរប្អូន។

ក៖   ប្អូននាក់?

ខ៖   ហ្នឹងហើយកូនទី....អានោះកូនមើលវាអាប្អូនអញ្ចឹងហើយវា   វាត្រូវហើយវាងាប់អស់មួយទាំងអស់ប្រាំពិលវាងាប់មួយ។

ក៖   ចាំ   អញ្ចឹងចៅចៅ។

ខ៖   ប្រាំពិលនឹងហើយនៅប្រាំមួយ។

ក៖   ចៅនៅសល់ប្រាំមួយនាក់?

ខ៖   នៅសល់ប្រាំមួយនាក់នៅតូចៗនឹងក្មួយឯងមើលធ្វើអី។

ក៖   ចាំ។

ខ៖   រួចទៅឪពុកទៅរត់ម៉ូតូជួលផ្ទះគេរួចយកកូននោះមើលយកមកអោយឯងមើលមកចូលរៀននឹង។

ក៖ ចាំ ចុះអ្នកមីងធ្លាប់មានបទពិសោធន៍ល្អៗក្នុងជិវិតដែរអត់ធ្លាប់មានទេ?

ខ៖ មីងមើលទៅមួយជិវិតនេះដូចរកភាពអោយសប្បាយមិនទាន់ឃើញទេ ក្មួយអើយព្រោះកូនវានៅអត់មានដោះស្រាយអីចេញជំរកជ្រកកោននៅឡើយ មីងដូចអត់សប្បាយចិត្តសោះហើយក៍មីងនឹងក៍គ្មានលទ្ធភាពអីជួយ។

ក៖ ចុះនៅពេលដែលអ្នកមីងនៅក្មេងអ្នកមីងធ្លាប់មានអើ...ការគិតក្តីសង្ឃឹមមួយថាអ្នកមីងធំឡើងចង់បានអីចង់ធ្វើធីជាងគេ?

ខ៖ អ៎រ...មីងចេះចង់បានចង់អា....កាលពីនៅអាយុនែកនៅរៀនថ្នាក់ទីមួយមកត្រឹមទីពីរហើយមកត្រឹមមកដាច់អាពតនឹងណាស់នៅក្នុងកំឡុងអាពតនឹងណាស់។

ក៖ ចាំ។

ខ៖ តែចេះតែគិតឃើញត្រឹមមាសយករើសមកបានក៍មិនដឹងយកទៅបើកអាជីពស្អីបើអត់ចាយលុយសោះ។

ក៖ ចាំ។

ខ៖ យើងទៅធ្វើការបាន បានស៊ីបើយើងមិនទៅធ្វើការបានអីហូបបើចានឆ្នាំងអត់មានគេអត់អោយមានអង្ករមួយគ្រាប់ក្នុងផ្ទះផងនឹង។

ក៖ ចាំ។

ខ៖ តែគេដឹងយើងដាំបាយស៊ីនៅក្នុងផ្ទះគេសំលាប់យើងចោល។

ក៖ ចាំ។

ខ៖ អញ្ចឹងបានថាជិវិតថ្ងៃរស់ភ័យយប់បើយប់បានរស់មួយយប់ទល់ភ្លឺ រស់មួយថ្ងៃទៀតយប់ឡើងភ័យបើកភ្នែកឡើងភ័យមិនដឹងងាប់ថ្ងៃមិនដឹងងាប់យប់ព្រោះគេយកវាយចោល(សំលាប់ចោល)ព្រោះកំពុងធ្វើៗការអញ្ចឹងហាំផ្លុំកញ្ចែរច្រេកកំពុងតែជុំរះៗផ្លុំកញ្ចែរច្រេកគេរើសកូនសក្តិភូមិគេរើសកូនអ្នកមានជាន់ ជាន់មុនអញ្ចឹងហាំពីសង្គមអ្នកមានអញ្ចឹងហាំ។

ក៖ ចាំ។

ខ៖ គេយកទៅវាយចោលហើយ។

កៈ ចា៎។

ខៈ ដាក់រទេះសេះយកវាយទម្លាក់អណ្តូងហើយ។

កៈ អ៎រ...។

ខៈ ហ្នឹងអញ្ចឹងជំនាន់អាពតហា៎។

កៈ ចា៎អ្នកមីង។

ខៈ គេយកវាយចោលមីងឆ្អែតហើយជី....ជីវគ្គមួយជិវិតនេះកើតមកដឹងក្តីចូលនឹមអាពតគ្មានភាពអីអោយមានសេរីភាពមកដំណាក់កាលនេះមានកូនក៏មិនទាន់សប្បាយចិត្តនៅឡើយវានៅខ្វះខាតគ្រប់បែបគ្រប់យ៉ាងអាណិតចៅបើមានកង់ក៏ដុបចៅទៅរៀនក៏មិនកើតជើងវាទន់អញ្ចឹងគ្នាដើរទៅតូចៗពេក។

កៈ តូចៗនៅពិបាកយកទៅផ្ញើដាក់...។

ខៈ ហ្នឹងហើយរួចយកទៅផ្ញើសាលាមតេយ្យរួចទៅ ទៅដើរពីនាក់បងប្អូនទៅ។

កៈ សាលានៅឆ្ងាយទេអ្នកមីង?

ខៈ ប្រហែលជាមីងមិនចេះវ៉ាស់ម៉ែត្រគីឡូអីទេក្មួយដូចជាឆ្ងាយដែរណាស់ដើរមួយហាត់ដែរណា។

កៈ ចា៎។

ខៈ ចំនែកមីងដើរមួយហាត់ដែរណា។

កៈ ហ៊ៃក្មេងតូចៗ។

ខៈ ហ្នឹងហើយទៅៗ។

កៈ ចុះអ្នកមីងមានអីផ្តែផ្តាំទៅកូនចៅជំនាន់ក្រោយទេនៅពេលដែលគាត់បានស្តាប់វីខតនឹងទៅអោយគាត់មានបទពិសោធន៍មានអី។

ខៈ អ្ហូ....ចេះប្រាប់ហើយថាក្មួយឯងណាស់នែក កើតមកនៅក្នុងសង្គមនេះណាស់សំណាងហើយកើតមកគេសង្គមគេជឿនលឿនម៉ាជំនាន់មីងហា៎កើតមកស៊ីបាយអាពតទេជាងបាយជ្រូ

កទៀតមកជំនាន់នេះសង្គមនេះអ៊ីនធើណេតដូចអាទិទេពចង់និយាយមួយពាន់គីឡូដីក៍ឃើញមុខគ្នាជំនាន់មីងចប់ដឹងក្តីមកចូលអាពតក្មួយឯងសំណាងហើយដែលបានប្រាប់ថាជំនាន់អាពតមិនមែនបានសប្បាយអីចែសទេក្មួយវាតូចៗប៉ុនក្មួយឯង

វាមិនអោយស៊ីបាយអត់ប្រយោជន៍ទេធ្វើកូនប៉ោតមួយដួសបង្គន់អាចម៍បង្គន់យកទៅធ្វើជីហើយដើរមកកន្ត្រៀងខែតចិញ្ច្រាំប្រលាក់ជាមួយអាចម៍នឹងទៅដាក់ហាលថ្ងៃ៕

កៈ ចាំ។

ខៈ ហ្នឹងហាំក្មេងៗហាំ។

កៈ ចាំ។

ខៈ ដួសអាចម៍បង្គន់ដង្កូវជជ្រេកនឹងហាំយកមកដាក់នឹងវាហាលអញ្ចឹងទៅដើមកន្ត្រៀងខែតនឹងកាប់ចិញ្ច្រាំយកហាលអោយស្ងួតទៅលាមកនឹងស្ងួតហើយយកមកជ្រៀវយកទៅបាចជីដាក់ជីស្រែ៕

កៈ ចាំ អញ្ចឹងអ្នកមីងមានអីផ្តែផ្តាំសម្រាប់ក្មេងៗជំនាន់ក្រោយ?

ខៈ អើបានថាក្មួយៗដែលក្មួយឯងសំណាងហើយណាស់ធ្វើបុណ្យល្អណាស់ដែលមកជួបនឹងបច្ចុប្បន្ននេះសង្គមអភិវឌ្ឍន៍ជឿនលឿន ជឿនលឿនសប្បាយណាស់អញ្ចឹងបានថាបើសប្បាយកុំសប្បាយភ្លេចខ្លួនបើផឹកស៊ីស្តាយអាយុជិវិតកុំអាងអីៗកាប់ចាក់ចាញ់គេដេកផ្ទះឈ្នះគេដេកព្រៃណាក្មួយអោយចាំមួយម៉ាត់នឹង៕

កៈ ចាំ។

ខៈ ឃើញវាផឹកស៊ីកុំបើកបរណាក្មួយបើស្រវឹងហើយដេកមួយកន្លែងទៅប្រយ័ត្នមានគ្រោះថ្នាក់យើងប្រយ័ត្នអាគេមិនប្រយ័ត្នរួចអាការផឹកហើយស្រវឹងវាមិនដែលស្រួលទេ។

កៈ ចាំ។

ខៈ អញ្ចឹងកុំទៅណាមកណាយើងស្តាយសង្គមគេកំពុងអភិវឌ្ឍន៍ទៅមុខជឿនលឿនណាស់។

កៈ ចាំ។

ខ៖ ស្គាយមិនងាប់វិលល្វាចទេអ៊ីយអាញ់ស្រលាញ់ប្រាប់ថាស្រលាញ់ហាំបានមីងនិយាយបើមីងនិយាយទៅអោយអាក្រក់ដេកគិតមើលទៅ។

ក៖ ចាំ។

ខ៖ អ៊ុំឯងនិយាយត្រូវហើយអញ្ចឹងបានស្គាយអាយុជិវិត។

ក៖ ចាំ។

ខ៖ ផឹកស៊ីអោយចេះស្រលាញ់ខ្លួន។

ក៖ ចាំ។

ខ៖ មិនអញ្ចឹង?

ក៖ ចាំអ្នកមីង។

ខ៖ នឹងផ្តែផ្តាំអញ្ចឹង។

ក៖ អញ្ចឹងជាចុងក្រោយនេះញុំអរគុណអ្នកមីងដែលបានជួយផ្តល់..អរគុណអ្នកមីងដែលបានជួយផ្តល់.....ពេលវេលាដ៏សំខាន់អោយខ្ញុំបានសំភាសន៍អ្នកមីងពីជីវប្រវត្តិផ្ទាល់ខ្លួនហើយអើ....ចំពោះជីវប្រវត្តិទាំងអស់នឹងខាងពួកខ្ញុំនឹងដាក់ទៅក្នុងអើ...គេហទំព័រមួយហើយអើ...ពួកញុំនឹងដាក់វាទៅក្នុងវេបផ្សាយហើយខាងពួកខ្ញុំក៏មានចែកអើជាឌីសដល់អ្នកមីងវិញទុកគ្រាន់ស្តាប់ហើយអោយកូនចៅបានស្តាប់ ហើយពួកខ្ញុំសូមអនុញ្ញាតិអ្នកមីងដើម្បីដាក់អើ..ប្រវត្តិរបស់អ្នកមីងដែលបានសំភាសន៍ថ្ងៃនឹងទៅក្នុងវេបផ្សាយអ្នកមីងអនុញ្ញាត្តិអត់?

ខ៖ ឥឡូវបើ...ក្មួយដាក់ក៏ដាក់ចុះបើក្មួយពេញចិត្តនឹងដែលមីងសំភាសន៍នឹងក្មួយដាក់ក៏ដាក់ចុះ។

ក៖ ចាំ...អញ្ចឹងអរគុណច្រើនអ្នកមីងសម្រាប់ការសំភាសន៍ថ្ងៃនេះសូមជូនពរអោយអ្នកមីងមានសុខភាពល្អ។

ខ៖ អឺ..។

ក៖ ចាំ។

ខ៖ អឺ.. អឺ..។

ក៖ ចាំ អញ្ចឹងជំរាបលាអ្នកមីង។

ខ៖ មីងក៏អរគុណក្មួយដែលបានមកសំភាសន៍មីងចង់ដឹងពីជីវប្រវត្តិពីជំនាន់មីងហើយក្មួយក៏កើតមិនទាន់ដែរ៕

ក៖ ចាំ។

ខ៖ មិនអញ្ចឹង។

ក៖ ចាំ។

ខ៖ ក្មួយកើតមិនទាន់ទេអញ្ចឹងបានថាក្មួយចង់ដឹងជីវការរស់នៅពីអាណាត្តិជំនាន់មីងនឹងពីប៉ែតពីខែ..ចិត្តគត់នឹងហៃសដាច់ហៃសក្នុងអាពត។

ក៖ ចិតប្រាំ(១៩៧៥)។

ខ៖ ក្នុងចិតប្រាំហាំ.....?

ក៖ ចាំ។

ខ៖ ក្នុងជំនាន់ចិតប្រាំនឹងមីងនិយាយពីជំនាន់នៅក្នុងដាច់ទេណា។

ក៖ ចាំ។

ខ៖ កាលនៅក្នុងអាពតវានៅក្នុងកំឡុងប៉ុន្មានឆ្នាំប៉ុន្មាន?

ក៖ ចិតសិបចិតប្រាំ(១៩៧៥)។

ខ៖ សង្គ្រាមបីឆ្នាំបីឆ្នាំប៉ុន្មានខែហើយមក មួយថ្ងៃដូចមួយខែយើងអញ្ចឹងក្មួយមួយជំនាន់អាពតថាវាយូរអើយយូរ។

ក៖ ចាំ។